ទីស្តីការគណៈរដ្ឋមន្ត្រី

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# អំពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តកម្ពុជា

ការិយាល័យវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

ខែ មិថុនា ឆ្នាំ២០១២

# មាតិកា


| | | |
|---|---|---|
| សេចក្តីផ្តើម | | ៥ |
| តើអ្វីទៅជាការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(RIA) ? | | ៦ |
| ដំណាក់កាលទាំងពីរក្នុងវិធីអនុវត្ត RIA | | ៧ |
| RIA នៅក្នុងរបៀបតាក់តែងបទប្បញ្ញត្តិ | | ៨ |
| ការវាយតម្លៃបឋម (PA) | | ៩ |
| របៀបសម្រេច | | ១០ |
| ការកំណត់បញ្ហា | (ចំណុចទី១: បញ្ហា) | ១៣ |
| បង្ហាញពីគោលដៅនៃកិច្ចអន្តរាគមន៍ | (ចំណុចទី២: ការបង្ហាញគោលដៅ) | ១៤ |
| ការជ្រើសរើសនូវជម្រើសសម្រាប់ធ្វើការវិភាគ | (ចំណុចទី៣ : ជម្រើស) | ១៦ |
| ការពិចារណាលើបន្ទុកចំណាយ និងផលចំណេញ | (ចំណុចទី៤: ការវិភាគផលប៉ះពាល់) | ១៧ |
| ការវិភាគតាមក្រុមក្នុងសង្គម និងតាមគុណភាព | | ២២ |
| ប្រសិទ្ធភាពនៃការពិគ្រោះយោបល់ | (ចំណុចទី៥: ការពិគ្រោះយោបល់) | ២៣ |
| ការជ្រើសរើសនូវជម្រើសដែលចូលចិត្តជាង | (ចំណុចទី៦: ការសន្និដ្ឋាន) | ២៤ |
| ការធានាថាបញ្ញត្តិកម្មរបស់អ្នកអាចអនុវត្តបាន | (ចំណុចទី៧: ការអនុវត្ត) | ២៥ |
| ឯកសារភ្ជាប់ | (ទម្រង់ការវាយតម្លៃបឋម និងបញ្ជីត្រួតពិនិត្យ) | ២៨ |

## អំពីគម្រោង នៃការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA) កម្ពុជា

គម្រោង (RIA) នៅកម្ពុជា សំដៅពង្រឹងការប្រកួតប្រជែងនិងប្រសិទ្ធភាពនៃបញ្ញត្តិកម្ម តាមរយៈការស្ថាបនានូវគោលការណ៍ប្រតិបត្តិទម្លាប់ល្អ ក្នុងការតាក់តែងបទប្បញ្ញត្តិនៅតាមស្ថាប័នរាជរដ្ឋាភិបាល។ ប្រព័ន្ធ RIA តម្រូវឲ្យក្រសួងនីមួយៗ អនុវត្តតាមគោលការណ៍ប្រតិបត្តិទម្លាប់ល្អ និងវាយតម្លៃលើ គុណូបការៈនៃបទប្បញ្ញត្តិ ដែលមានផលប៉ះពាល់ដល់បន្ទុកចំណាយកាតព្វកិច្ច និងការប្រកួតប្រជែងរបស់ធុរកិច្ច។

ក្នុងគម្រោងនេះ ក្រុមការងារអនុវត្តគម្រោងនៃការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (ORIA) ត្រូវបានបង្កើតឡើងនៅក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីផ្តល់នូវការជួយទ្រទ្រង់ដល់ក្រសួងស្ថាប័នពាក់ព័ន្ធ លើគោលការណ៍ប្រតិបត្តិទម្លាប់ល្អក្នុងការតាក់តែងបទប្បញ្ញត្តិ ការបណ្តុះបណ្តាលអំពី RIA និងគាំទ្រដល់ក្រសួងពាក់ព័ន្ធក្នុងការអនុវត្ត RIA និងទទួលគ្រប់គ្រងដំណើរការនៃគម្រោង។

ភ្នាក់ងារអនុវត្តគម្រោង (IA) រួមមាន ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងទេសចរណ៍ នឹងពិសោធវិធីអនុវត្ត RIA ក្នុងអំឡុងពេលនៃដំណើរការបណ្តុះបណ្តាលនៃគម្រោង ដើម្បីអភិវឌ្ឍ RIA សម្រាប់បញ្ញត្តិកម្មដែលបានកំណត់នៅក្នុងផែនការសកម្មភាពដែល IA បានលើកឡើងក្នុងអំឡុងពេលចាប់ផ្តើមគម្រោងក្នុងឆ្នាំ២០១១។

គម្រោងមានរយៈពេល ៣០ខែ ចាប់ពីឆ្នាំ ២០១១ ២០១២ ២០១៣ និងបញ្ចប់នៅឆ្នាំ២០១៤ ដែលអនុវត្តដោយ ORIA និង IA និងមានជំនួយពីក្រុមទីប្រឹក្សាអន្តរជាតិ និងអ្នកជំនាញក្នុងប្រទេស។

សម្រាប់ព័ត៌មានលំអិតអំពីគម្រោង RIA ក្នុងប្រទេសកម្ពុជា អាចចូលមើលក្នុងគេហទំព័រ (ecosocc.gov.kh)។ របាយការណ៍ចាប់ផ្តើមអនុវត្តគម្រោង និងផែនការសកម្មភាពរបស់ IA នីមួយៗ គឺជាប្រភពនៃព័ត៌មានដែលមានប្រយោជន៍។ ប្រសិនបើអ្នកចង់យល់ដឹងទិដ្ឋភាពរួមពី RIA អ្នកអាចទាក់ទងជាមួយមន្ត្រី ORIA ដើម្បីឲ្យមន្ត្រី ORIA ធ្វើបទបង្ហាញជូន។

## អំពីគោលការណ៍ណែនាំ

គោលការណ៍ណែនាំនេះ បង្ហាញអំពីវិធីអនុវត្ត RIA ក្នុងប្រទេសកម្ពុជា និងតម្រូវឲ្យបំពេញតាមចំណុចនីមួយៗនៃការវាយតម្លៃលើផល់ប៉ះពាល់ឲ្យបានត្រឹមត្រូវ ។ គោលបំណងគឺជួយមន្ត្រីរាជរដ្ឋាភិបាលក្នុងការរៀបចំបទប្បញ្ញត្តិ និងផ្តល់នូវព័ត៌មានបានសុក្រឹតដល់អ្នកធ្វើសេចក្តីសម្រេច។

គោលការណ៍ណែនាំនេះ គឺជាឯកសារមូលដ្ឋានមួយ។ សេចក្តីព្រាងលើកទីមួយនេះ មានគោលបំណងជួយដល់មន្ត្រីក្នុងអំឡុងពេលបង្កើត ORIA និងអភិវឌ្ឍ RIA សម្រាប់សំណើបញ្ញត្តិកម្មដែលមានក្នុងផែនការសកម្មភាពរបស់ IA នីមួយៗ។ ដូច្នេះ សេចក្តីព្រាងនេះផ្តោតសំខាន់លើការបង្ហាញគោលកាណ៍ប្រតិបត្តិទម្លាប់ល្អក្នុងការតាក់តែងបទប្បញ្ញត្តិ និងបង្ហាញទិដ្ឋភាពទូទៅនៃវិធីអនុវត្តRIA។

អត្ថបទក្រោយ នឹងបន្ថែមនូវព័ត៌មានអំពី RIA ក្នុងដំណើរការតាក់តែងបញ្ញត្តិកម្មក្នុងប្រទេសកម្ពុជា ជាបន្តបន្ទាប់។

## ការវាយតម្លៃជាប្រព័ន្ធនៃសំណើបញ្ញត្តិកម្មថ្មី

បំណង RIA គឺដើម្បីកែលម្អភាពមាំមួននៃការធ្វើច្បាប់ក្នុងប្រទេសកម្ពុជា ដោយធានាថា:

- ជម្រើសនីមួយៗត្រូវបានយកមកពិចារណាដោយធានាបាននូវប្រសិទ្ធភាពរបស់បញ្ញត្តិកម្មដែលនឹងត្រូវបង្កើត
- បញ្ញត្តិកម្មមិនត្រូវបានធ្វើ នៅពេលដែលវាបង្ហាញថាជម្រើសមិនល្អ
- មានការពិគ្រោះយោបល់ជាសាធារណៈក្នុងកម្រិតទទួលយកបាន

ការអនុវត្តការវាយតម្លៃជាប្រព័ន្ធនៃសំណើបញ្ញត្តិកម្ម ដែលមានចំណុចទាំង៧ (តារាង១) នឹងធ្វើឲ្យបញ្ញតិកម្មត្រូវបានធ្វើការសាកល្បង ហើយជម្រើសនីមួយៗត្រូវបានយកមកពិចារណា ដោយស្មើៗគ្នា។

គោលការណ៍បីនឹងណែនាំអំពីការរៀបចំ RIA :

- **ការកែលម្អព័ត៌មានសម្រាប់អ្នកធ្វើសេចក្តីសម្រេច** RIA នឹងផ្តល់ព័ត៌មានស្តីពីបន្ទុកចំណាយ និងផលចំណេញនៃសំណើបញ្ញត្តិកម្ម និងជម្រើសដែលសម្រេចនូវគោលដៅដល់អ្នកធ្វើសេចក្តីសម្រេច ប្រកបដោយព័ត៌មានសុក្រឹតគ្រប់គ្រាន់។
- **ភាពងាយស្រួល** ភាគច្រើននៃផលចំណេញនានារបស់ RIA អាចទទួលបានតាមរយៈ ការពិគ្រោះយោបល់ ហេតុផលសមរម្យ ងាយស្រួលគណនា និងការសាកល្បងលើការសន្មត ជាជាងតាមរយៈការអនុវត្តបច្ចេកទេសស្មុគស្មាញ។ ដូច្នេះការធ្វើ RIA នៅកម្ពុជានឹងមានភាពងាយស្រួលអាចដំណើការទៅបាន។
- **តម្លាភាព** តម្លាភាពអាចធ្វើឲ្យមានការពិគ្រោះយោបល់បានត្រឹមត្រូវ និងមានអភិបាលកិច្ចល្អ ហើយសម្រេចបានដោយចំណាយតិច តាមរយៈការបង្ហោះព័ត៌មានលើគេហទំព័រ។ ដើម្បីជួយដល់អាជីវកម្មតូចៗដែលមិនមានលទ្ធភាពប្រើប្រាស់ Internet ភាពងាយស្រួលមើលឯកសារសាធារណៈត្រូវរក្សាទុក ដើម្បីឲ្យភាគីពាក់ព័ន្ធអាចមើលឯកសារនោះបាន។

ការលើកស្ទួយតម្លាភាពនឹងជួយឲ្យសម្រេចគោលដៅចុងក្រោយរបស់គម្រោង។

## តារាងទី១- ចំណុចទាំងប្រាំពីរនៃ RIA ៖

### បញ្ហា

- កំណត់អត្តសញ្ញាណនៃបញ្ហាដែលត្រូវដោះស្រាយ។ រៀបរាប់ពីសញ្ញាបុព្វហេតុ និងអ្នកដែលរងផលប៉ះពាល់។ ផ្តល់ភស្តុតាងជាក់លាក់និងពន្យល់ថាហេតុអ្វីបានជាលិខិតបទដ្ឋានដែលមានស្រាប់មិនអាចដោះស្រាយបាន។

### គោលដៅ

- កំណត់គោលដៅដែលត្រូវអន្តរាគមន៍ ក្នុងរូបភាពជាលទ្ធផល ជាជាងជាមធ្យោបាយដើម្បីសម្រេចបានលទ្ធផល។

### ជម្រើស

- កំណត់ជម្រើសផ្សេងៗ ដោយបោះបង់ចោលនូវជម្រើសដែលមិនអាចដោះស្រាយបញ្ហាបានឬមិនសមស្រប និងរៀបរាប់ពីជម្រើសដែលអាចដោះស្រាយបញ្ហាបាន ដោយលម្អិត។

### ការវិភាគផលប៉ះពាល់

- កំណត់ និងប៉ាន់ស្មានលើបន្ទុកចំណាយ និងផលចំណេញ ក៏ដូចជាវាយតម្លៃផលប៉ះពាល់យេនឌ័រនិងការប្រកួតប្រជែងនៃជម្រើសទាំងនោះ។

### ការពិគ្រោះយោបល់

- ធ្វើការពិគ្រោះយោបល់ជាមួយអ្នកដែលពាក់ព័ន្ធក្នុងអំឡុងពេលរៀបចំ PA ឬ RIS និងប្រើប្រាស់លទ្ធផលនៃការពិគ្រោះយោបល់នោះ ដើម្បីបំពេញបន្ថែមដល់ចំណុចទី៦ផ្សេងទៀតរបស់ RIA។

### សេចក្តីសន្និដ្ឋាន

- កំណត់ជម្រើសដែលចូលចិត្តជាងជម្រើសដែលមានប្រសិទ្ធភាពបំផុតដើម្បីសម្រេចគោលដៅនៃការអន្តរាគមន៍និងផ្តល់នូវផលចំណេញខ្ពស់ដល់សង្គម។

### ការអនុវត្ត

- ពន្យល់ថា តើជម្រើសដែលឃើញសមស្របជាងនោះ នឹងត្រូវបានអនុវត្តនិងវាយតម្លៃ យ៉ាងដូចម្តេច?

## តម្រង់គោលដៅអនុវត្ត RIA ឲ្យចំទិស

ដើម្បីឲ្យការងាររដ្ឋបាលមានភាពងាយស្រួលនិងនីតិវិធីមានប្រសិទ្ធភាព វីធីអនុវត្ត RIA តាមពីរដំណាក់កាលត្រូវបានស្នើឡើងសម្រាប់អនុវត្តក្នុងប្រទេសកម្ពុជា

- រាល់សំណើបញ្ញត្តិកម្មដែលមានផលប៉ះពាល់ដល់ធុរកិច្ច តម្រូវឲ្យធ្វើ **ការវាយតម្លៃបឋម** (PA)
- ប្រសិនបើការវាយតម្លៃបឋមបង្ហាញថា សំណើបញ្ញត្តិកម្មនោះមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ នោះតម្រូវឲ្យធ្វើ **ការវាយតម្លៃពេញលេញ** (RIS)។

ដំណាក់កាលនៃដំណើរការនេះត្រូវបានបង្ហាញក្នុងរូបភាពដូចខាងក្រោម ៖

ទាំង PA ទាំង RIS ត្រូវមានការវិភាគតាមចំណុចទាំង៧របស់ RIA ។ គោលបំណងរបស់ PA គឺវាយតម្លៃឲ្យបានរហ័សលើសំណើបញ្ញត្តិកម្ម ដើម្បីបង្ហាញថាតើ សំណើបញ្ញត្តិកម្មនោះមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ឬទេ។ សំណើបញ្ញត្តិកម្ម ដែលមិនមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ មិនតម្រូវឲ្យធ្វើការវិភាគបន្តទៀតទេ។ សំណើបញ្ញត្តិកម្ម ដែលមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ តម្រូវឲ្យធ្វើ RIS ដោយមានការវាយតម្លៃស៊ីជម្រៅ។

- ការតម្រូវឲ្យមាន PA ចំពោះសំណើបញ្ញត្តិកម្មទាំងអស់ នឹងធានាថាពុំមានសំណើបញ្ញត្តិកម្មណាគេចផុតពីការត្រួតពិនិត្យយ៉ាងហ្មត់ចត់បានទេ
- ការតម្រូវឲ្យធ្វើRIS នឹងធានាថា ការវាយតម្លៃបានធ្វើលើរាល់សំណើបញ្ញត្តិកម្មណាដែលមានផលប៉ះពាល់គួរកត់សម្គាល់។

ក្នុងអំឡុងពេលនៃដំណាក់កាលបណ្តុះបណ្តាលនៃគម្រោង មានតែសំណើបញ្ញត្តិកម្មរបស់ទីភ្នាក់ងារអនុវត្តទេ ដែលនឹងតម្រូវឲ្យធ្វើPA ហើយសំណើបញ្ញត្តិកម្មមួយចំនួនដែលមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ នឹងត្រូវធ្វើRIS។

## រូបភាពទី១ : ទិដ្ឋភាពរួមនៃដំណាក់កាលទាំងពីរក្នុងការអនុវត្ត RIA



## រូបភាពទី២ - កែសម្រួលរបៀបតាក់តែងបញ្ញត្តិកម្មក្នុងប្រទេសកម្ពុជា

បញ្ញត្តិកម្មស្នើឡើងដោយក្រសួង

ដំណើរការថ្មី

PA ឬ RIS :
-រៀបចំដោយក្រសួងគាំទ្រដោយ ORIA
-ពិនិត្យដោយ ORIA

ច្បាប់ ព្រះរាជក្រឹត្យ និងអនុក្រឹត្យ

- ពិចារណាដោយអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ពិចារណានៅក្នុងកិច្ចប្រជុំជំនាញបច្ចេកទេស
- ពិចារណានៅក្នុងកិច្ចប្រជុំអន្តរក្រសួង
- ពិចារណានៅក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ
- សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

ប្រកាស បទបញ្ជា និងសារាចរ

- សម្រេចដោយរដ្ឋមន្ត្រី

## RIA និងរបៀបតាក់តែងបញ្ញត្តិកម្ម

RIAផ្តល់ព័ត៌មានពីបន្ទុកចំណាយ និងផលចំណេញ និងជម្រើសផ្សេងៗដែលអាចធ្វើឲ្យសម្រេចគោលបំណងដូចគ្នាជូនអ្នកធ្វើសេចក្តីសម្រេចដើម្បីឲ្យគាត់មានព័ត៌មានគ្រប់គ្រាន់ក្នុងការសម្រេច។

រូបភាពទី២បង្ហាញពីភាពស៊ីចង្វាក់របស់ RIA ក្នុងដំណើរការតាក់តែងបញ្ញត្តិកម្ម នៅក្នុងប្រទេសកម្ពុជា។ RIA ត្រូវបានរៀបចំឡើងដោយក្រសួងដែលកំណត់ពីភាពចាំបាច់នៃកិច្ចអន្តរាគមន៍របស់រាជរដ្ឋាភិបាល ហើយដាក់សំណើបញ្ញត្តិកម្មជូនអ្នកធ្វើសេចក្តីសម្រេច។

- ចំពោះច្បាប់ ព្រះរាជក្រឹត្យ និងអនុក្រឹត្យ ក្រសួងសាមីត្រូវរៀបចំ PA និង RIS ប្រសិនបើតម្រូវ មុននឹងដាក់សំណើបញ្ញត្តិកម្មជូនអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល។
- ចំពោះប្រកាស បទបញ្ជា និងសារាចរ ក្រសួងសាមីត្រូវរៀបចំPA និង RISប្រសិនបើតម្រូវ មុននឹងដាក់សំណើបញ្ញត្តិកម្មជូនរដ្ឋមន្ត្រីរបស់ខ្លួន។

## វិធីអនុវត្ត RIA ក្នុងដំណាក់កាលបណ្តោះអាសន្ន

ក្នុងអំឡុងពេលនៃដំណាក់កាលបណ្តុះបណ្តាលនៃគម្រោង វិធីអនុវត្ត RIA នឹងប្រតិបត្តិតែលើសំណើបញ្ញត្តិកម្មណាដែលមាននៅក្នុងផែនការសកម្មភាពរបស់ IA។

នៅដំណាក់កាលដំបូង IA និង ORIA សហការគ្នាក្នុងការធ្វើ PA និង RIS ដោយមានជំនួយពីអ្នកជំនាញការអន្តរជាតិ ដើម្បីរៀនសូត្រពីវិធីនៃការធ្វើវិភាគឲ្យបានល្អ។

ក្នុងឆ្នាំ២០១២ ORIA ដើរតួនាទីជាអ្នកកសាងសមត្ថភាពនិងជាអ្នកវាយតម្លៃ។ IA នឹងរៀបចំ PA និង RIS ដោយគ្មានឬមានជំនួយតិចតួចពីអ្នកជំនាញការអន្តរជាតិ (ជំនួយនឹងត្រូវផ្តល់ដោយ ORIA។ PA/RIS នឹងត្រូវដាក់ជូន ORIA ដើម្បីពិនិត្យ។

សង្ឃឹមថា នៅពេលដែលសមត្ថភាពចេះធ្វើនិងវាយតម្លៃ RIA ត្រូវបានអភិវឌ្ឍរួច ដំណើរការខាងលើនេះនឹងត្រូវអនុវត្តដោយក្រសួងទាំងអស់។

## ការវាយតម្លៃបឋម

**ការវាយតម្លៃបឋម** (PA) ត្រូវបានធ្វើឡើងដោយប្រើប្រាស់ទម្រង់ដូចមានក្នុងឧបសម្ព័ន្ធ១ ហើយចាប់ផ្តើមសាកល្បងថាតើសំណើបញ្ញត្តិកម្មឈានដល់កម្រិតដែលត្រូវវិភាគ RIS ឬទេ។

ដំណាក់កាលដំបូងនៃការសាកល្បងនេះ គឺដើម្បីកំណត់ថាតើសំណើនោះមានលក្ខណៈជាបញ្ញត្តិកម្មឬទេ មានន័យថា តើសំណើនោះមានលក្ខណៈចាប់បង្ខំបុគ្គល ធុរកិច្ច ឲ្យផ្លាស់ប្តូរឥរិយាបទឬទេ។ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសគឺជាបញ្ញត្តិកម្ម។ ឯកសាររដ្ឋាភិបាលផ្សេងទៀតដែលមានលក្ខណៈចាប់បង្ខំធុរកិច្ចក៏មានលក្ខណៈជាបញ្ញត្តិកម្មផងដែរ។

ដំណាក់កាលទី២នៃការសាកល្បងនេះ គឺកំណត់ថាតើសំណើនោះមានផលប៉ះពាល់ដល់ធុរកិច្ចឬទេ។ ផលប៉ះពាល់ដល់ធុរកិច្ចមានស្ថានភាពដូចខាងក្រោម ៖

- បន្ថែមបន្ទុកចំណាយដល់ធុរកិច្ច
- មិនលើកទឹកចិត្តដល់វិនិយោគឯកជន
- ដាក់ការរឹតត្បិតចំពោះការចាកចេញ ឬការចូលទៅក្នុងទីផ្សាររបស់ធុរកិច្ច
- ប៉ះពាល់ដល់លទ្ធភាពរបស់ធុរកិច្ចក្នុងការច្នៃប្រឌិត
- ធ្វើឲ្យអ្នកប្រើប្រាស់មានការពិបាកក្នុងការផ្លាស់ប្តូរអ្នកផ្តល់សេវា
- កាត់បន្ថយភាពងាយស្រួល ដល់ការរកទិញ តម្លៃឬគុណភាពទំនិញ និងសេវានៅក្នុងទីផ្សារ។

ប្រសិនបើស្ថានភាពខាងលើនេះកើតឡើងចំពោះធុរកិច្ចមែន នោះតម្រូវឲ្យបន្តធ្វើ PA ទៅតាមចំណុចទាំង៧នៃRIA ដោយឈរលើមូលដ្ឋាននៃការវិភាគគុណភាព ថ្វីបើការវាយតម្លៃលើផលប៉ះពាល់នោះជាបរិមាណក៏ជាការអនុវត្តល្អដែរ។

សេចក្តីព្រាង PA នឹងត្រូវដាក់ជូន ORIA ដើម្បីពិនិត្យ។

ប្រសិនបើ PA បង្ហាញថាមានផលប៉ះពាល់តិចតួច នោះមិនតម្រូវឲ្យវិភាគតទៅទៀតទេ។ ដាក់ PA និងសំណើបញ្ញត្តិកម្មជូនអ្នកធ្វើសេចក្តីសម្រេច និងបង្ហោះលើគេហទំព័រ ECOSOCC។

## រូបភាពទី៣ - ការសាកល្បង

| | |
|---|---|
| ដំណាក់កាលទី១ : តើសំណើនោះជាបញ្ញត្តិកម្មឬ? | តើសំណើបញ្ញត្តិកម្មមានលក្ខណៈចាប់បង្ខំឬ? តើមានការបង្ខំឲ្យអនុវត្តជាជាងការអនុវត្តដោយស្ម័គចិត្ត? |
| ដំណាក់កាលទី២ : តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់ដល់ធុរកិច្ចឬទេ? | •តាមរយៈ ៖<br>• បន្ថែមបន្ទុកចំណាយដល់ធុរកិច្ច<br>• មិនលើកទឹកចិត្តដល់វិនិយោគឯកជន<br>• ដាក់ការរឹតត្បិតធុរកិច្ចក្នុងការចាកចេញ និងការចូលទៅក្នុងទីផ្សារ<br>• ប៉ះពាល់លទ្ធភាពរបស់ធុរកិច្ចក្នុងការច្នៃប្រឌិត<br>• ធ្វើឲ្យអ្នកប្រើប្រាស់មានការពិបាកក្នុងការផ្លាស់ប្តូរអ្នកផ្តល់សេវា<br>• កាត់បន្ថយ ភាពងាយស្រួលដល់ការរកទិញតម្លៃ ឬគុណភាពទំនិញ នឹងសេវានៅក្នុងទីផ្សារ |

## សំណួរដែលតែងតែសួរពាក់ព័ន្ធនឹងការវាយតម្លៃបឋម?

*តើខ្ញុំត្រូវធ្វើការវាយតម្លៃបឋម(PA)ដែរឬទេ?*

ប្រសិនបើសំណើបញ្ញត្តិកម្មត្រូវបានយកមកពិចារណា អ្នកត្រូវធ្វើPA ដើម្បីវាយតម្លៃថាតើសំណើនោះមានផលប៉ះពាល់ដល់ធុរកិច្ចឬទេ។

*តើខ្ញុំធ្វើយ៉ាងណា ដើម្បីឲ្យដឹងថាបន្ទុកចំណាយទាប?*

បន្ទុកចំណាយទាបកើតឡើងនៅពេលដែលមានធុរកិច្ចមួយចំនួនតូចទទួលរងផលប៉ះពាល់ ឬធុរកិច្ចមានបន្ទុកចំណាយតែមួយដង។

*តើខ្ញុំត្រូវគិតពីផលចំណេញដែរឬទេ ខណៈពេលគិតពីផលប៉ះពាល់?*

ផលប៉ះពាល់ដល់ធុរកិច្ចគួរត្រូវបានវាយតម្លៃលើបន្ទុកចំណាយ ឬលើផលប៉ះពាល់អវិជ្ជមានតែប៉ុណ្ណោះ។ បន្ទុកចំណាយមិនគួរទូទាត់នឹងផលចំណេញទេនៅដំណាក់កាលនេះ។ ការអនុវត្តនេះជាផ្នែករបស់ RIA។

## ដំណើរការព្រាង និង វាយតម្លៃ




## ការរៀបចំនិងការវាយតម្លៃ RIA

វិធីអនុវត្ត RIA ប្រតិបត្តិដោយ ORIA ជាមួយមន្ត្រីនៃ IA។

IA នឹងទទួលខុសត្រូវក្នុងការកំណត់សំណើបញ្ញត្តិកម្ម ដែលនឹងត្រូវធ្វើ RIS។

បន្ទាប់ពីបានកំណត់សំណើបញ្ញត្តិកម្ម IA នឹងរៀបចំ PA។ IA អាចស្នើសុំជំនួយ ឬការណែនាំពី ORIA ដើម្បីបញ្ចប់សេចក្តីព្រាង PA របស់ខ្លួន។ IA ផ្ញើសេចក្តីព្រាង PA ចុងក្រោយមក ORIA ដើម្បីពិនិត្យ។

ORIA ពិនិត្យវិនិច្ឆ័យសេចក្តីព្រាង PA ដោយធ្វើការផ្ទៀងផ្ទាត់ជាមួយបញ្ជីត្រួតពិនិត្យដែលមានក្នុងឧបសម្ព័ន្ធ២ និង វាយតម្លៃថាគ្រប់គ្រាន់ ឬមិនទាន់គ្រប់គ្រាន់។ ប្រសិនបើវាមិនទាន់គ្រប់គ្រាន់ PA នោះនឹងត្រូវផ្ញើត្រឡប់ទៅ IA វិញដោយភ្ជាប់យោបល់របស់ ORIA ។ IA នឹងធ្វើការកែសម្រួលតាមយោបល់របស់ ORIA រហូតដល់សេចក្តីព្រាង PA នោះមានគុណៈគ្រប់គ្រាន់ (ដំណើរការនេះអាចធ្វើច្រើនដង)។

ក្នុងករណីសេចក្តីព្រាងPAមានលក្ខណៈគ្រប់គ្រាន់ IAនឹងធ្វើRIS ប្រសិនបើតម្រូវ រួចដាក់PAនិងសំណើបញ្ញត្តិកម្មជូនអ្នកធ្វើសេចក្តីសម្រេច។

ការវិភាគក្នុង RIS ត្រូវអនុវត្តដូចធ្វើ PA ។

## វិធីអនុវត្ត RIA ក្នុងដំណាក់កាលបណ្តោះអាសន្ន

ក្នុងដំណាក់កាលបណ្តុះបណ្តាល ORIAនិងIA នឹងសហការគ្នាក្នុងការធ្វើ PA/RIS ខណៈពេលកំពុងសិក្សាអំពីចំណុចទាំង៧របស់RIA តាមរយៈវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាដែលរៀបចំដោយទីប្រឹក្សាអន្តរជាតិ។

ដំណើរការខាងលើនេះនឹងចាប់ផ្តើមអនុវត្តនៅពេល IA និង ORIA មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការព្រាងនិងវាយតម្លៃ PAនិង RIS។

# ចំណុចទាំងប្រាំពីរនៃការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

## ចំណុចទី១ - បញ្ហា

ដំណាក់កាលទី១នៃវ.ផ.ល. គឺកំណត់លក្ខណៈនិងទំហំនៃបញ្ហាដែលត្រូវដោះស្រាយ។

ការរកឲ្យឃើញបញ្ហាដែលកើតមានឡើងមានសារៈសំខាន់ មុននឹងសម្រេចថាតើ អន្តរាគមន៍របស់រដ្ឋាភិបាល ដូចជាការដាក់បញ្ញត្តិកម្ម គឺជាការចាំបាច់ឬទេ។ ប្រសិនបើមិនបានយល់ច្បាស់លាស់ពីប្រភេទលក្ខណៈ និងទំហំនៃបញ្ហាទេ សំណើបញ្ញត្តិកម្មនោះអាចមិនគ្រប់គ្រាន់ មិនសមរម្យ ឬមិនមានប្រសិទ្ធភាព។

ការកំណត់បញ្ហាឲ្យបានច្បាស់លាស់ ជួយឲ្យមានការផ្តោតការចាប់អារម្មណ៍ទៅលើអ្វីដែលចាំបាច់ត្រូវផ្លាស់ប្តូរ និងទំហំនៃការផ្លាស់ប្តូរនោះនឹងអាចជួយរកដំណោះស្រាយដែលមានសក្តានុពល។

កិច្ចអន្តរាគមន៍របស់រដ្ឋាភិបាលអាចមានហេតុផលត្រឹមត្រូវ ដើម្បីសម្រេចគោលបំណងសង្គមឬបរិស្ថាន ដែលមិនអាចធ្វើឲ្យសម្រេចតាមរយៈទីផ្សារ។ កិច្ចអន្តរាគមន៍ទាំងនេះមានដូចខាងក្រោម ៖

- កែតម្រូវភាពបរាជ័យនៃទីផ្សារ។
- ជំរុញលទ្ធផលឲ្យមានសមធម៌ ឬស្តង់ដារអប្បបរិមានៃការរស់នៅក្នុងសហគមន៍។
- ធានាសុវត្ថិភាពសង្គម ដោយការពារប្រជាជនពីឧក្រិដ្ឋកម្ម និងអំពើរំលោភបំពាន។

### បញ្ជីត្រួតពិនិត្យ - តើអ្នកអាចឆ្លើយសំណួរដូចខាងក្រោមនេះបានឬទេ?"

តើបញ្ហានោះធំកម្រិតណា និងមានផលវិបាកធ្ងន់ធ្ងរកម្រិតណា?

អ្វីជាផលប៉ះពាល់នៃបញ្ហា និងនរណារងផលប៉ះពាល់នោះ?

តើអ្នកមានភស្តុតាងឬឧទាហរណ៍ ដើម្បីគាំទ្របញ្ហានោះទេ?

ហេតុអ្វីបានជាបញ្ញត្តិកម្មដែលមានស្រាប់មិនអាចដោះស្រាយបញ្ហានោះបាន?

តើមានអ្វីកើតឡើង ប្រសិនបើមិនចាត់វិធានការលើបញ្ហានោះ?

តើកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាលអាចដោះស្រាយបញ្ហានោះបានឬទេ?

## *ការកែតម្រូវភាពបរាជ័យនៃទីផ្សារ*

ជាទូទៅទីផ្សារដែលដំណើរការល្អបានផ្តល់មធ្យោបាយមានប្រសិទ្ធភាពក្នុងការបែងចែកទំនិញនិងសេវានៅក្នុងសហគមន៍ ធ្វើឲ្យមានសុខុមាលភាពច្រើននៅក្នុងសហគមន៍។ ទីផ្សារគឺជាមធ្យោបាយដ៏ល្អបំផុតក្នុងការធានាឲ្យមានការផលិតទំនិញនិងសេវាប្រកបដោយប្រសិទ្ធភាព។ ម្យ៉ាងទៀត ទីផ្សារប្រកួតប្រជែងជំរុញឲ្យមានការច្នៃប្រឌិតនិងផ្តល់ជម្រើសកាន់តែច្រើនសម្រាប់អ្នកប្រើប្រាស់។

ទោះបីជាយ៉ាងណាក៏ដោយ មានករណីខ្លះ ទីផ្សារមិនបានផ្តល់លទ្ធផលល្អសម្រាប់សង្គមទេ ឧទាហរណ៍ ដោយសារទីផ្សារដំណើរការមិនល្អ ឬមិនមានការប្រកួតប្រជែងពេញលេញ។ ដូច្នេះ រដ្ឋាភិបាលអាចមានហេតុផលត្រឹមត្រូវក្នុងការធ្វើអន្តរាគមន៍ ដើម្បីធ្វើឲ្យមានលទ្ធផលសេដ្ឋកិច្ចកាន់តែប្រសើរ។ ប៉ុន្តែហេតុនៃបរាជ័យទីផ្សាររួមមាន ៖

• ***អំណាចទីផ្សារ*** -រចនាសម្ព័ន្ធទីផ្សារមិនមានការប្រកួតប្រជែង(ផ្តាច់មុខឬស្ទើរតែផ្តាច់មុខ) ឈ្មួញនិងឥរិយាបថប្រឆាំងនឹងការប្រកួតប្រជែង (ការឃុបឃិតគ្នា) អាចបណ្តាលឲ្យថ្លៃកើនឡើង ឬលទ្ធផលទាបជាងចំណុចដែលល្អបំផុត។ រដ្ឋាភិបាលអាចអន្តរាគមន៍ ដើម្បីធានាថាមិនមានការប្រើប្រាស់អំណាចទីផ្សារដែលធ្វើឲ្យអ្នកប្រើប្រាស់ខាតប្រយោជន៍។

• ***កត្តាសាយភាយ*** -កើតឡើងនៅពេលសកម្មភាពមួយដាក់បន្ទុកចំណាយ(មិនបានទូទាត់សងវិញ) ឬបង្កើតផលចំណេញ (មិនចែករំលែក) ដល់អ្នកពាក់ព័ន្ធផ្សេងទៀត។ កត្តាសាយភាយអាចធ្វើឲ្យសកម្មភាពមួយអាចកើតឡើងច្រើនហួស ឬ តិចពេក។ រដ្ឋាភិបាលអាចអន្តរាគម ដើម្បីធានាឲ្យមានការយកចិត្តទុកដាក់លើការដាក់បន្ទុកចំណាយនិងផលចំណេញទាំងនោះ។

• ***ព័ត៌មានមិនគ្រប់គ្រាន់*** -ដើម្បីសម្រេចឲ្យបានត្រឹមត្រូវ អ្នកប្រើប្រាស់ត្រូវមានព័ត៌មានអំពីគុណភាពឬហានិភ័យរបស់ផលិតផល។ រដ្ឋាភិបាលអាចអន្តរាគម ដើម្បីធានាថា អ្នកលក់ត្រូវតែបង្ហាញព័ត៌មានសំខាន់ៗដល់អ្នកប្រើប្រាស់។

• ***ទំនិញសាធារណៈ*** -គឺជាទំនិញឬសេវាដែលប្រើប្រាស់ដោយអ្នកខ្លះមិនត្រូវបានកាត់បន្ថយចំនួនសម្រាប់អ្នកប្រើប្រាស់ដទៃទៀត (មិនប្រកួតប្រជែង) និងគ្មាននរណាអាចរារាំងការប្រើប្រាស់បានទេ (មិនហាមឃាត់)។ ទំនិញសាធារណៈអាចផ្គត់ផ្គង់មិនបានគ្រប់គ្រាន់ ប្រសិនបើគ្មានកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល។

## ហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់មិនគ្រប់គ្រាន់?

សារៈសំខាន់នៃការកំណត់បញ្ហាដែលបានកើតឡើង គឺត្រូវពិនិត្យលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ និងបង្ហាញថាលិខិតបទដ្ឋានគតិយុត្តទាំងនោះមិនអាចដោះស្រាយបញ្ហាបាន។

ការពិនិត្យនេះធានាថា បញ្ញត្តិកម្មថ្មី នឹងបង្កើតឡើងនៅពេលដែលចាំបាច់។ របៀបនេះនាំមកនូវការសម្របសម្រួលច្រើន ចំពោះដំណើរការតាក់តែងបញ្ញត្តិកម្មរបស់ក្រសួង ស្ថាប័ននានា។

ការពិចារណាដោយប្រុងប្រយ័ត្នលើបញ្ញត្តិកម្មដែលមានស្រាប់អាចជួយកំណត់ជម្រើសផ្សេងៗផងដែរ។ ការកែលម្អការតាក់តែងបញ្ញត្តិកម្ម ឬការកែលម្អការអនុវត្តលិខិតបទដ្ឋានដែលមានស្រាប់ អាចដោះស្រាយបញ្ហាបានដោយចំណាយតិចជាងការបង្កើតបញ្ញត្តិកម្មថ្មី។

## ការផ្តល់ភស្តុតាងចំពោះបញ្ហា

ការកំណត់បញ្ហាគឺមិនគ្រប់គ្រាន់ទេសម្រាប់ចំណុចទី១នៃRIA។ ការផ្តល់ភស្តុតាងចំពោះបញ្ហាដែលបានកើតឡើងមានសារៈសំខាន់។

ភស្តុតាងអាចផ្តល់ក្នុងទម្រង់ជាស្ថិតិ ករណីសិក្សា ឬឧទាហរណ៍ដោយផ្អែកលើទំហំនិងផលវិបាកនៃបញ្ហា។ ប្រសិនបើបញ្ហាកាន់តែសំខាន់ត្រូវមានទិន្នន័យកាន់តែរឹងមាំ។

ស្ថិតិអំពីទំហំនៃបញ្ហា -ប្រមូលដោយរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឬអ្នកពាក់ព័ន្ធ/អ្នកស្រាវជ្រាវផ្សេងទៀត -គឺជាទម្រង់នៃភស្តុតាងរឹងមាំ។

ទោះបីជាយើងត្រូវការភស្តុតាងទាំងនេះក៏ដោយ ក៏ភស្តុតាងទាំងនេះពិបាករកឬត្រូវចំណាយច្រើនដែរ។ ក្នុងករណីនេះ ការប្រើប្រាស់ករណីសិក្សាអាចទទួលយកបាន ឬផ្តល់ឧទាហរណ៍មួយៗនៃបញ្ហា។

ទិន្នន័យពីប្រទេសផ្សេងដែលមានសេដ្ឋកិច្ចភូមិសាស្ត្រ សង្គម និង/ឬវប្បធម៌ស្រដៀងគ្នានឹងប្រទេសកម្ពុជា អាចប្រើជាទិន្នន័យជំនួសសម្រាប់ភស្តុតាងបឋមផងដែរ។

## ចំណុចទី២ : គោលដៅ

ដោយបានកំណត់បញ្ហា ដែលត្រូវដោះស្រាយតាមរយៈកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល ចំណុចបន្ទាប់របស់ RIA គឺកំណត់គោលដៅនៃកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល។ ការកំណត់គោលដៅនឹងផ្តល់នូវមូលដ្ឋានគោល ដើម្បីសាកល្បងទម្រង់ផ្សេងៗនៃកិច្ចអន្តរាគមន៍។

វាមានសារៈសំខាន់ ដែលគោលដៅត្រូវបានកំណត់ជាលទ្ធផលនៃកិច្ចអន្តរាគមរបស់រដ្ឋាភិបាលដោយតាំងចិត្តធ្វើ និងវាមិនមែនជាទម្រង់នៃកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាលទេ។ នោះវាអនុញ្ញាតឲ្យមានជម្រើសផ្សេងៗ ដែលត្រូវវាយតម្លៃឲ្យបានត្រឹមត្រូវ។

- ការកំណត់គោលដៅជាវិធីធ្វើឲ្យសម្រេចលទ្ធផល នឹងនាំឲ្យការវិភាគលំអៀងទៅរកជម្រើសជាក់លាក់ណាមួយ។

ឧទាហរណ៍ -រដ្ឋាភិបាលធ្វើអន្តរាគមន៍ជាច្រើន ដើម្បីកាត់បន្ថយការបាត់បង់ជីវិតដោយគ្រោះថ្នាក់ចរាចរ ដោយតម្រូវឲ្យអ្នកបើកបរម៉ូតូពាក់មួកសុវត្ថិភាព កំណត់ល្បឿនបើកបរ និងត្រួតពិនិត្យភ្លើងចរាចរនៅផ្លូវបំបែកជាបួន។ នៅពេលពិចារណាពីសំណើបញ្ញត្តិកម្មថ្មី ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរ គោលដៅគួរកំណត់ថា "ពង្រឹងសុវត្ថិភាពចរាចរ" ឬក៏អ្វីស្រដៀងគ្នា។ ប្រសិនបើកំណត់គោលដៅដោយតម្រូវឲ្យ "ពាក់មួកសុវត្ថិភាព" នេះនឹងរារាំងការពិចារណាជម្រើសល្អៗជាច្រើនទៀត។

ជៀសវាងការកំណត់គោលដៅទូលាយពេកឬចង្អៀតពេក ៖

- គោលដៅទូលាយពេកនឹងធ្វើឲ្យការវិភាគមិនច្បាស់លាស់ (ឧទាហរណ៍សម្រាប់សុខុមាលភាពប្រជាជន)។
- គោលដៅចង្អៀតពេករឹតត្បិតជម្រើស

គោលដៅដែលបានជ្រើសរើស គួរពិចារណាលើកត្តាផ្សេងទៀត ដែលអាចផ្ទុយនឹងគោលដៅរបស់រដ្ឋាភិបាល។ បើពុំនោះទេ កិច្ចអន្តរាគមន៍របស់រដ្ឋាភិបាលអាចលុបចោលគំនិតផ្តើមផ្សេងទៀត។ ឧទាហរណ៍ គោលដៅនៃកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការប្រើប្រាស់ថាមពលនៅតាមគេហដ្ឋាន គួរពិចារណាផងដែរលើលទ្ធភាពទិញគេហដ្ឋាន ប្រសិនបើវាជាគោលដៅរបស់រដ្ឋាភិបាល។

## គោលដៅ S.M.A.R.T.

គុណភាពនៃគោលដៅ និងតម្លៃដែលបានបន្ថែមដល់ការវិភាគនឹងមានភាពប្រសើរឡើង ប្រសិនបើគោលការណ៍ S.M.A.R.T ត្រូវបានអនុវត្ត។

| | |
|---|---|
| ជាក់លាក់ (SPECIFIC) | ផ្តល់សេចក្តីលម្អិត ដើម្បីឲ្យការវិភាគមានន័យ។ គោលដៅមិនច្បាស់លាស់នាំឲ្យការប្រឹងប្រែងខុសទិសដៅ។ សូមប្រុងប្រយ័ត្ន កុំបញ្ជាក់ពីវិធីដែលធ្វើឲ្យសម្រេចគោលដៅពិព្រោះវាអាចទាត់ចោលជម្រើសល្អៗផ្សេងទៀត។ |
| អាចវាស់បាន (MEASURABLE) | ការកំណត់តួលេខក្នុងគោលដៅ ជួយយើងពន្យល់ពីលទ្ធភាពដែលនឹងអាចសម្រេចបាន។ ការនេះនឹងធ្វើឲ្យការប្រៀបធៀបជម្រើសផ្សេងៗ កាន់តែប្រសើរឡើង ដោយសារការវិភាគអាចវាស់ថាតើ គោលដៅរបស់ជម្រើសនីមួយៗនៅឆ្ងាយកម្រិតណា។ |
| អាចសម្រេចបាន (ATTAINABLE) | ភាពឥតខ្ចោះមិនតែងតែអាចសម្រេចបាននោះទេ។ ឧទាហរណ៍ រដ្ឋាភិបាលមិនអាចលុបបំបាត់ហានិភ័យទាំងអស់បានទេ។ ការកំណត់គោលដៅទៅតាមលទ្ធភាពរបស់រដ្ឋាភិបាល នឹងជួយបញ្ចៀសការអះអាងខុសអំពីផលចំណេញទៅថ្ងៃក្រោយ។ |
| ពាក់ព័ន្ធ (RELEVANT) | គោលដៅគួរបន្សុំទៅនឹងការទទួលខុសត្រូវ និងសមត្ថភាពរបស់ក្រសួង ស្ថាប័ន។ ប្រសិនបើបញ្ហាដែលត្រូវដោះស្រាយ ហួសពីការទទួលខុសត្រូវរបស់អ្នក អ្នកអាចពិចារណាថាតើ សំណើបញ្ញត្តិកម្មនោះសមរម្យឬទេ។ |
| រយៈពេល (TIMEFRAME) | បញ្ជាក់ពីរយៈពេលក្នុងការធ្វើឲ្យសម្រេចគោលដៅ។ ភាពប្រសើរមិនអាចកើតឡើងក្នុងរយៈតែមួយថ្ងៃបានទេ។ ការផ្លាស់ប្តូរលឿនពេកអាចផ្តល់លទ្ធផលមិនសូវល្អ។ ការសម្រេចគោលដៅក្នុងរយៈពេលមួយសមស្របជាការល្អ។ |

## ឧទាហរណ៍ទី១

រដ្ឋាភិបាលអូស្ត្រាលីកំពុងបង្កើតបណ្តាញរលកអាកាសជាតិ ដើម្បីឲ្យប្រជាជនអូស្ត្រាលីភាគច្រើនប្រើប្រាស់រលកអាកាសល្បឿនលឿនបាន។

ក្នុងករណីនេះ គោលបំណង ឬ គោលដៅ គឺប្រជាជនអូស្ត្រាលីអាចប្រើប្រាស់អ៊ិនធឺណែតដែលមានល្បឿនលឿន។

មធ្យោបាយមួយក្នុងចំណោមមធ្យោបាយជាច្រើន (ឬវិធីសាស្ត្រ) ដើម្បីសម្រេចគោលដៅនេះគឺរដ្ឋាភិបាលសាងសង់បណ្តាញខ្សែកាបអុបទិក។ មធ្យាបាយផ្សេងទៀតរួមមានឧបត្ថម្ភធនដល់ការតភ្ជាប់ក្នុងតំបន់ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មរបស់ក្រុមហ៊ុនឯកជនទេ។ ការតភ្ជាប់នៅក្នុងទីក្រុងសំខាន់ៗនឹងអាចផ្តល់ជូនជាលក្ខណៈពាណិជ្ជកម្ម។

ដើម្បីកំណត់គោលដៅក្នុងការបង្កើតបណ្តាញរលកអាកាសជាតិ គឺជាការសម្រេចជាក់លាក់តែមួយគត់ ដែលមិនស្ថិតនៅក្នុងក្របខណ្ឌRIAទេ ពីព្រោះវាធ្វើឲ្យការវិភាគមានភាពលម្អៀងធៀបនឹងជម្រើសផ្សេងទៀតដែលសម្រេចគោលដៅដូចគ្នា។

## ឧទាហរណ៍ទី២

រដ្ឋាភិបាលចង់ដោះស្រាយបញ្ហាក្មេងពុល បន្ទាប់ពីលេបថ្នាំដែលទុកចោលនៅក្នុងផ្ទះ។

សំណើបញ្ញត្តិកម្មត្រូវបានតាក់តែងឡើងដើម្បីសម្រេចគោលដៅ ដោយធ្វើឲ្យដបថ្នាំពិបាកបើក។ ទោះបីជាយ៉ាងណា ក្មេងពុលបន្ទាប់ពីលេបថ្នាំដែលទុកចោលនៅក្នុងផ្ទះមានចំនួនកើនឡើង ពីព្រោះមនុស្សចាស់មិនអាចបើកគំរបដបថ្នាំបាន ហើយនៅពេលគេបើកបាន គេក៏ជំនួសគំរបថ្មីដើម្បីងាយបើកលើកក្រោយ។

សំណើបញ្ញត្តិកម្មត្រូវបានតាក់តែងឡើង ដើម្បីសម្រេចគោលដៅកាត់បន្ថយការប្រើប្រាស់ថ្នាំដោយក្មេងៗ។ ជាមួយនឹងគោលដៅទូលាយនេះ ដំណោះស្រាយគឺផ្សព្វផ្សាយអប់រំឪពុកម្តាយ ឲ្យទុកដាក់ដបថ្នាំកុំឲ្យក្មេងយកបាន ដាក់ស្លាកព្រមានលើដបថ្នាំ ធ្វើដបថ្នាំឲ្យងាយបើកសម្រាប់តែអ្នកដែលអាចអានអក្សរបាន។ វិធានការនេះកាត់បន្ថយចំនួនក្មេងពុលបាន។

## ចំណុចទី៣ - ជម្រើស

ជម្រើស គឺ ជាវិធីដោះស្រាយដទៃទៀតដែលអាចធ្វើឲ្យសម្រេចគោលដៅដែលបានកំណត់។ ជម្រើសទាំងនោះ ជាមធ្យោបាយខុសៗគ្នាដើម្បីសម្រេចគោលដៅ។

រាល់ការវិភាគផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ត្រូវពិចារណាពីជម្រើសផ្សេងៗ។ ជាពិសេស ជម្រើសមិនមែនបញ្ញត្តិកម្មនិងជម្រើសមិនស្មុគស្មាញ គួរត្រូវយកមកពិចារណាជាមួយនឹងសំណើបញ្ញត្តិកម្ម។ ប្រសិនបើRIAពិចារណាតែសំណើបញ្ញត្តិកម្ម នោះមិនធានាថាជ្រើសរើសបានជម្រើសដ៏ល្អប្រសើរនោះទេ។

ដើម្បីជ្រើសរើសជម្រើស គួរបង្កើតតារាងបញ្ជីជម្រើស។ ចំនួនជម្រើសត្រូវបានកាត់បន្ថយ ដោយដកចេញជម្រើសដែលមិនអាចអនុវត្តបានដូចជា ជម្រើសដែលមិនអាចធ្វើបានឬរំលោភលើអនុសញ្ញាអន្តរជាតិជាដើម។

បន្ទាប់ពីជម្រើស៣ទៅ៤ (ករណីខ្លះ មានច្រើនជាងនេះ) នៃការជ្រើសរើសចុងក្រោយត្រូវបានកំណត់ ជម្រើសនីមួយៗគួរអធិប្បាយឲ្យបានលម្អិតល្អម ដើម្បីឲ្យអ្នកពាក់ព័ន្ធយល់ពីអ្វីដែលបានស្នើ និងធ្វើការប្រៀបធៀបជម្រើសទាំងនោះនៅក្នុងផ្នែកវិភាគផលប៉ះពាល់។

ព័ត៌មានបន្ថែមអំពីជម្រើសផ្សេងៗដែលអ្នកអាចពិចារណា មាននៅក្នុងការវិភាគរបស់អ្នក ដែលបានបង្ហាញនៅផ្នែកខាងស្តាំដៃ។

## ការណែនាំ - តើការជ្រើសរើសជម្រើសរបស់អ្នកត្រឹមត្រូវឬទេ?

ជម្រើសទាំងអស់ត្រូវតែអនុវត្តបាននៅក្នុងក្របខណ្ឌលិខិតបទដ្ឋានគតិយុត្ត ដែលមានស្រាប់ អនុសញ្ញាអន្តរជាតិ រចនាសម្ព័ន្ធសង្គមនិងវប្បធម៌

ជម្រើសមិនមែនបញ្ញត្តិកម្មគួរពិចារណានៅរាល់ការអនុវត្តRIA លើកលែងតែជម្រើសនោះមិនអាចធ្វើបាន។

ជម្រើសនីមួយៗគួរអធិប្បាយឲ្យបានលម្អិតល្អម ដើម្បីឲ្យអ្នកពាក់ព័ន្ធយល់នូវអ្វីដែលបានស្នើ និងធ្វើការប្រៀបធៀបជម្រើសទាំងនោះនៅក្នុងផ្នែកវិភាគផលប៉ះពាល់។

## ឧទាហរណ៍នៃជម្រើសបញ្ញត្តិកម្ម និង ជម្រើសមិនមែនបញ្ញត្តិកម្ម

ជម្រើសមិនមែនបញ្ញត្តិកម្ម ៖

- ព័ត៌មានសាធារណៈនិងយុទ្ធនាការអប់រំ -ប្រសិទ្ធភាពយុទ្ធនាការអប់រំអាចសម្រេចគោលដៅ ដោយគ្មានការចាប់បង្ខំតាមរយៈបញ្ញត្តិកម្ម។
- ការផ្តល់រង្វាន់ដល់ការផ្លាស់ឥរិយាបថល្អ។

ឧបករណ៍ទីផ្សារ

•សិទ្ធិធ្វើពាណិជ្ជកម្ម (ឧទាហរណ៍ សិទ្ធិធ្វើពាណិជ្ជកម្មទឹក)។

•ពន្ធនិងឧបត្ថម្ភធន(ឧទាហរណ៍ ដាក់ពន្ធលើភេសជ្ជៈស្រវឹងនិងថ្នាំជក់)។

ការកែលម្អលិខិតបទដ្ឋានដែលមានស្រាប់

- ពង្រឹងការអនុវត្តបទបញ្ញត្តិដែលមានស្រាប់។
- ពង្រីកវិសាលភាពនៃលិខិតបទដ្ឋានដែលមានស្រាប់។

បញ្ញត្តិកម្មមានកម្រិតស្រាល

- **ស្វ័យគ្រប់គ្រង** -ក្រុមហ៊ុនឯកភាពគ្នាលើគោលការណ៍មួយចំនួនដែលពួកគេស្ម័គ្រចិត្តអនុវត្ត (ករណីនេះ អាចមានប្រសិទ្ធភាពនៅពេលហានិភ័យទាប និងឧស្សាហកម្មមានការប្រមូលផ្តុំ ដោយមានការទទួលខុសត្រូវ និងសមាគមឧស្សាហកម្មមានឥទ្ធិពល)។
- **សហបញ្ញត្តិកម្ម** -នៅពេលរដ្ឋាភិបាលនិងឧស្សាហកម្មសហការគ្នាក្នុងការតាក់តែងនិងពង្រឹងការអនុវត្តច្បាប់។ យើងប្រើប្រាស់ជម្រើសនេះនៅពេលជំនាញបច្ចេកទេសមានសារៈសំខាន់។
- **បញ្ញត្តិកម្មវិជ្ជមាន** -ការទទួលស្គាល់គុណភាពទំនិញឬសេវាល្អ ឥរិយាបថល្អ ការគ្រប់គ្រងល្អរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនទទួលបានបណ្ណសរសើរដែលមានកិត្តិនាមនៅក្នុងទីផ្សារ។
- **អាជ្ញាបណ្ណអវិជ្ជមាន** -ការព្រមានដកអាជ្ញាបណ្ណពីក្រុមហ៊ុនឬបុគ្គលដែលបានទទួលអាជ្ញាបណ្ណធ្វើអ្វីមួយ ដោយមិនបំពេញតាមលក្ខខណ្ឌកំណត់។
- **បញ្ញត្តិកម្មផ្អែកលើហានិភ័យ** -តម្រូវការបញ្ញត្តិកម្មនឹងប្រែប្រួលទៅតាមហានិភ័យនៃសកម្មភាពដែលបានដាក់បញ្ញត្តិ។ សកម្មភាពទាំងឡាយដែលបង្កើតហានិភ័យ ដោយមានផលវិបាកតិចតួចកើតឡើង គេអាចដាក់បញ្ញត្តិកាន់តែស្រាល។

## ចំណុចទី ៤- ការវាយតម្លៃផលប៉ះពាល់

បញ្ញត្តិកម្មតម្រូវឲ្យមានបន្ទុកចំណាយចំពោះរដ្ឋាភិបាល ធុរកិច្ច និងបុគ្គល។ បញ្ញត្តិកម្មដែលមានប្រសិទ្ធភាពនឹងផ្តល់នូវផលចំណេញផងដែរ ស្របពេលដែលគោលបំណងរបស់រដ្ឋាភិបាលបានសម្រេច។

ការវិភាគផលប៉ះពាល់ផ្តល់ឲ្យអ្នកធ្វើសេចក្តីសម្រេច នូវព័ត៌មានគ្រប់គ្រាន់ក្នុងការថ្លឹងថ្លែងពីផលប៉ះពាល់វិជ្ជមាននិងអវិជ្ជមាន។ ប្រសិនបើអ្នកធ្វើសេចក្តីសម្រេចជ្រើសរើសការធ្វើបញ្ញត្តិកម្ម ដោយមិនមានការវិភាគពីផលប៉ះពាល់ នោះគោលបំណងមិនអាចសម្រេចបាន ឬជម្រើសដែលមានបន្ទុកចំណាយតិចនឹងត្រូវមើលរំលង។ ដូច្នេះតួនាទីរបស់ការវិភាគផលប៉ះពាល់គឺជួយអ្នកធ្វើសេចក្តីសម្រេច ចៀសវាងនូវកំហុសខាងលើនេះ។

ការវាយតម្លៃផលប៉ះពាល់ ត្រូវមានរូបភាពច្បាស់លាស់ អំពីដំណើរការរបស់បញ្ញត្តិកម្ម ដែលមិនបានពន្យល់លម្អិតនៅក្នុងសេចក្តីព្រាងបញ្ញត្តិកម្ម។ ឧទាហរណ៍: បញ្ញត្តិកម្មមួយអាចហាមឃាត់ការប្រើប្រាស់ជីរការដែលមានជាតិពុលសម្រាប់ការផលិតស្បែកជើងនៅកម្ពុជា។ ក៏ប៉ុន្តែបញ្ញត្តិកម្មនេះនឹងមិនថែងអំពី៖

- ជីរការជំនួស ឬ ដំណើរការផលិតស្បែកជើង ។
- តើអ្នកផលិតត្រូវធ្វើយ៉ាងណា ដើម្បីបង្ហាញថាពួកគាត់បានអនុវត្តតាមការហាមឃាត់នោះ។
- តើរដ្ឋាភិបាលនឹងអះអាងដោយរបៀបណា ដែលថាតើករណីខាងលើនេះជាបញ្ហាដែលត្រូវដោះស្រាយ។

គោលបំណងនៃបញ្ញត្តិកម្មខាងលើនេះ គឺដើម្បីការពារកម្មករពីការជួលសន្លប់ ប៉ុន្តែបញ្ញត្តិកម្មនេះនឹងមិនមានប្រសិទ្ធភាពទេ ប្រសិនបើជីរការដែលជំនួសនោះនៅតែមានជាតិពុល ឬក៏ការហាមឃាត់នេះធ្វើឲ្យមានចំណាយខ្ពស់ក្នុងការផលិតស្បែកជើង។

ការវិភាគផលប៉ះពាល់មានតួនាទីដើម្បី៖

- កំណត់អត្តសញ្ញាណនៃការផ្លាស់ប្តូរឥរិយាបថ ដែលបណ្តាលមកពីជម្រើសនីមួយៗ
- បង្ហាញជាបរិមាណនូវភាពញឹកញាប់ នៃការកើតមានការផ្លាស់ប្តូរទាំងនេះ
- កំណត់បន្ទុកចំណាយ (ឬផលចំណេញ) នៃការផ្លាស់ប្តូរនីមួយៗទាំងនេះ។

## ការវិភាគផលប៉ះពាល់អាចមានទម្រង់ច្រើន

RIA ជារឿយៗត្រូវបានគេចាត់ទុកជាមធ្យោបាយដើម្បីធានាថា មានតែបញ្ញត្តិកម្មដែលលើកកម្ពស់សុខុមាភាពសង្គមប៉ុណ្ណោះ ត្រូវបានយកមកអនុវត្ត ដោយប្រើប្រាស់ទម្រង់បញ្ញត្តិកម្មដែលមានប្រសិទ្ធភាពបំផុត។ RIA ប្រើប្រាស់ឧបករណ៍វិភាគបន្ទុកចំណាយ និងផលចំណេញ (CBA) ដើម្បីបង្ហាញថា តើជម្រើសណាផ្តល់ផលចំណេញច្រើនជាងបន្ទុកចំណាយ និងជម្រើសណាដែលសម្រេចបានផលចំណេញតាមកំណត់ដោយមានបន្ទុកចំណាយតិច។

ក្នុងប្រព័ន្ធ RIA មានការប្រើប្រាស់ការវិភាពតាមបែប CBA ណាណាតិចតួចណាស់។ ការតម្រូវឲ្យបានស្តង់ដាវិភាគបែបនេះ ធ្វើឲ្យកម្ពុជាប្រឈមនឹងផលិតភាពទាប ដោយអាចធ្វើឲ្យមានការលំបាកក្នុងការធ្វើ PA ឬ RIS នាំឲ្យការបញ្ចប់ PA ឬ RIS បានតែមួយចំនួនតូចប៉ុណ្ណោះ។ ជំនួសមកវិញគោលការណ៍ណែនាំនេះ ជំរុញឲ្យមានការវិភាគផលប៉ះពាល់ ដែលមានគោលបំណងផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់អ្នកធ្វើសេចក្តីសម្រេច ក្នុងការប្រៀបធៀបជំរើសនីមួយៗ។

**ការកំណត់** ពីបន្ទុកចំណាយ និងផលចំណេញនៃបញ្ញត្តិកម្មជួយឲ្យអ្នកធ្វើសេចក្តីសម្រេចយល់ដឹងពេញលេញពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដែលបញ្ញត្តិកម្មអាចបង្កឡើង។

ជារឿយៗប្រសិទ្ធភាពនៃបញ្ញត្តិកម្មត្រូវបានរំពឹងទុកខ្ពស់ពេក។ ដូច្នេះទិន្នន័យស្តីពីវិសាលភាពនៃបញ្ហានិងជម្រើសនីមួយៗ ដែលឆ្លើយតបនឹងបញ្ហាមានសារប្រយោជន៍ណាស់។ ជាទូទៅ ការអនុវត្តតាមបញ្ញត្តិកម្មពាក់ព័ន្ធទៅនឹងសកម្មភាពច្រើន (ឧ. ការត្រួតពិនិត្យ) និងញឹកញាប់ជាងការរំពឹងទុក។ **ការកំណត់ពីបរិមាណ** នៃប្រសិទ្ធភាពរបស់ជម្រើសនិងបន្ទុកចំណាយ នឹងជួយឲ្យអ្នកធ្វើសេចក្តីសម្រេច អាចថ្លឹងថ្លែងបានល្អរវាងផលប៉ះពាល់វិជ្ជមាននិងអវិជ្ជមាននៃជម្រើសផ្សេងៗ។

**ការកំណត់ថ្លៃ** បន្ទុកចំណាយអាចត្រឹមតែអនុញ្ញាតឲ្យអ្នកធ្វើសេចក្តីសម្រេចធ្វើការជ្រើសរើសជម្រើសនីមួយៗ ដោយផ្អែកលើប្រសិទ្ធភាពបន្ទុកចំណាយ។ បន្ទុកចំណាយនិងផលចំណេញត្រូវបានគណនាជាតម្លៃដោយប្រើរង្វាស់សាមញ្ញ ដូចជាដុល្លារជាដើម។ យ៉ាងណាមិញ ការគណនាជាតម្លៃមិនអាចតែងតែធ្វើទៅបានគ្រប់កាលៈទេសៈនោះទេ ជាពិសេសក្នុងករណីគណនារកផលចំណេញ។ នៅពេលដែលការគណនាជារូបិយវត្ថុមិនអាចធ្វើទៅបាន លោកអ្នកអាចប្រើប្រាស់ការកំណត់ថ្លៃតាមបែបគុណភាព ឬតាមបែបអត្តនោម័ត ដើម្បីប្រៀបធៀបជម្រើសនីមួយៗ។

## ការកំណត់ពីបន្ទុកចំណាយរបស់បញ្ញត្តិកម្ម

ការអនុវត្តតាម (និងការដាក់ឲ្យអនុវត្ត) នៃបញ្ញត្តិកម្ម ត្រូវប្រើប្រាស់ធនធាន ដែលអាចយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀត។ **ថ្លៃឱកាស**នៃបញ្ញត្តិកម្ម គឺវេលាបាត់បង់ដោយមិនបានប្រើធនធានសម្រាប់គោលបំណងជំនួស ។ **ថ្លៃឱកាស**នៃធនធាន គឺអាចវាស់តាមតម្លៃវាបានក្នុងពេលប្រើប្រាស់ជំនួសប្រសើរបំផុត ឬក្នុងពេលប្រសើរបន្ទាប់ ។

ដំណាក់កាលដំបូងនៃការវិភាគផលប៉ះពាល់ គឺដើម្បីកំណត់ថាភាគីទាំងអស់នឹងផ្លាស់ប្តូរឥរិយាបថរបស់ពួកគេ ប្រសិនបើជម្រើសទាំងនោះត្រូវបានអនុវត្ត នឹងដើម្បីពិពណ៌នាពី**ថ្លៃឱកាស**នៃការផ្លាស់ប្តូរឥរិយាបថទាំងនេះ។

ធុរកិច្ច រដ្ឋាភិបាល និងបុគ្គលម្នាក់ៗ មិនត្រូវគិតគូរដល់ពេលវេលា និងប្រាក់ដែលអាចដាក់ឲ្យអ្នកដទៃប្រើប្រាស់ នៅពេលដែលគេប្រតិបត្តិតាមដាក់ឱ្យអនុវត្តបញ្ញត្តិកម្ម ឬបើមិនដូច្នោះទេ គេត្រូវទទួលផលប៉ះពាល់ដោយបញ្ញត្តិកម្ម។

ឧទាហរណ៍នៃ**ថ្លៃឱកាស**មានដូចខាងក្រោម៖

<u>សម្រាប់អ្នកប្រតិបត្តិតាមបញ្ញត្តិកម្ម</u>

•ពេលវេលា ដើម្បីបំពេញការងាររដ្ឋបាល និងដើម្បីការរង់ចាំ

•ប្រាក់ត្រូវចំណាយដើម្បីអនុវត្តតាមបញ្ញត្តិកម្ម និងការបង់កម្រៃផ្សេងៗ

<u>សម្រាប់បញ្ញត្តិករ</u>

•ពេលវេលា និងប្រាក់ ដើម្បីពង្រឹង និងអនុវត្ត

<u>សម្រាប់តតិយជន (អតិថិជន, អ្នកប្រកួតប្រជែង, អ្នកផ្គត់ផ្គង់) :</u>

•ពេលវេលា ប្រាក់ និងការបាត់បង់ឱកាស ដូចជា ការកាត់បន្ថយភាពងាយស្រួលរកទិញ តម្លៃ ឬគុណភាពសេវាកម្មទៅលើការផ្គត់ផ្គង់។

ក្រសួង ឬនាយកដ្ឋានដែលបានរៀបចំសេចក្តីព្រាងបញ្ញត្តិកម្មអាចមិនដឹងពីផលប៉ះពាល់ជាច្រើន នៅក្នុងដំណាក់កាលដំបូងនៃការវិភាគផលប៉ះពាល់ក្នុងការធ្វើ PA។ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនឹងជួយធានាថា រាល់បន្ទុកចំណាយទាំងអស់ត្រូវបានកំណត់ ដែលនឹងធ្វើឲ្យពួកគេបានយល់ដឹងកាន់តែច្បាស់អំពីបញ្ញត្តិកម្មនោះ ដែលនឹងធ្វើឲ្យពួកគេផ្លាស់ប្តូរឥរិយាបថយ៉ាងដូចម្តេច។

## ការកំណត់ពីផលចំណេញ

ផលចំណេញរបស់បញ្ញត្តិកម្ម គឺឆ្លុះបញ្ចាំងពីការធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពរបស់មនុស្ស ដើម្បីចៀសវាងនូវការខូចខាតឬការបាត់បង់សុខុមាលភាពរបស់មនុស្សដោយសារតែមិនមានបញ្ញត្តិកម្ម។

ជាធម្មតា ផលចំណេញចម្បងរបស់បញ្ញត្តិកម្មនិងជម្រើសដទៃទៀតដែលបានវិភាគនៅក្នុងRIA គឺងាយស្រួលក្នុងការកំណត់ និងសង្ឃឹមថាអាចសម្រេចបាន ដូចជា ការកាត់បន្ថយការស្លាប់ដោយគ្រោះថ្នាក់ ការការពារបរិស្ថាន ឬការការពារអ្នកប្រើប្រាស់។

ប្រសិនបើផលចំណេញចម្បងរបស់បញ្ញត្តិកម្ម មិនសម្រេចបានតាមគោលបំណងដែលបានជ្រើសរើស យើងត្រូវគិតពិចារណាឡើងវិញថាជម្រើស នោះត្រឹមត្រូវឬទេ។ ទោះបីជាយ៉ាងណាក៏ដោយ ផលចំណេញរបស់បញ្ញត្តិកម្ម និងជម្រើសដទៃទៀត អាចមិនត្រូវបានកម្រិតទៅនឹងគោលបំណងនោះទេ។ ឧទាហរណ៍: សកម្មភាពរបស់រដ្ឋាភិបាលកែលម្អឧបករណ៍អគ្គិសនីដើម្បីការពារបរិស្ថាន អាចផ្តល់ផលចំណេញដល់អ្នកប្រើប្រាស់ដោយកាត់បន្ថយចំណាយទៅលើអគ្គិសនី។

## ឧទាហរណ៍- ហេតុអ្វីបានជាការធ្វើបញ្ញត្តិកម្មមិនមែនជាផលប៉ះពាល់វិជ្ជមាន ឬផលចំណេញ?

រាជរដ្ឋាភិបាលកម្ពុជាតម្រូវឲ្យធុរកិច្ចចុះបញ្ជីផលិតផលដែលខ្លួនលក់ ដូច្នេះការចុះបញ្ជីផលិតផលនេះ គឺមិនមែនជាផលចំណេញរបស់ធុរជនទេ។

ទោះបីជាដូច្នេះក៏ដោយ ការចុះបញ្ជីនេះជួយឲ្យរដ្ឋាភិបាលតាមដានមើលថាតើក្រុមហ៊ុនណាដែលបានអនុញ្ញាតឲ្យផលិតទំនិញមានម៉ាកពាណិជ្ជត្រឹមត្រូវ ហើយក៏ជួយរដ្ឋាភិបាលក្នុងការត្រួតពិនិត្យនិងទប់ស្កាត់ការក្លែងបន្លំ។

ការទប់ស្កាត់ការក្លែងបន្លំ មានទាំងបន្ទុកចំណាយនិងផលចំណេញសម្រាប់ប្រទេសកម្ពុជា ដែលអាចធ្វើឲ្យមានតម្លៃខ្ពស់សម្រាប់អ្នកប្រើប្រាស់ ប៉ុន្តែវានឹងជួយទាក់ទាញការវិនិយោគនៅក្នុងប្រទេស។

ទោះបីជាយ៉ាងនេះក្តី ក្រុមហ៊ុនអន្តរជាតិដែលមានឈ្មោះផលិតផលល្បីៗបានមកបង្កើតរោងចក្រនៅកម្ពុជាកាន់តែច្រើនឡើងៗ ដោយពួកគេជឿជាក់ថា កម្មសិទ្ធិបញ្ញារបស់ពួកគេនឹងត្រូវបានការពារដោយរដ្ឋាភិបាល។ នេះគឺជាការវិនិយោគមួយ និងជាផលចំណេញនៃការចុះបញ្ជីផលិតផល ហើយព័ត៌មានដែលទទួលបានពីការចុះបញ្ជីនេះ អាចមានប្រយោជន៍សម្រាប់រដ្ឋាភិបាលនិងភាគីដែលពាក់ព័ន្ធផងដែរ។

## ការកំណត់បរិមាណបន្ទុកចំណាយនិងផលចំណេញ

ដំណាក់កាលទី២នៃការវិភាគផលប៉ះពាល់ គឺការកំណត់បរិមាណ(ឬការវាស់វែង) បន្ទុកចំណាយ និងផលចំណេញរបស់ជម្រើសនីមួយៗ។ ឧទាហរណ៍: ចំនួនពាក្យសុំដែលនឹងត្រូវចងក្រងទុក (គឺបន្ទុកចំណាយ) ចំនួនជីវិត ដែលត្រូវបានជួយសង្គ្រោះ (គឺផលចំណេញ)។

វាមានសារៈសំខាន់ណាស់ ដើម្បីធ្វើការបែងចែកនៅក្នុងដំណាក់កាលនេះ (ការកំណត់បរិមាណ) អំពីការកំណត់ថ្លៃបន្ទុកចំណាយ និងផលចំណេញ (ជារូបិយវត្ថុ)។ ការកំណត់បរិមាណនៃបន្ទុកចំណាយ និងផលចំណេញ អាចផ្តល់ជាព័ត៌មានដ៏មានប្រយោជន៍។ ឧទាហរណ៍: ប្រសិនបើជម្រើសមួយសង្ឃឹមថា អាចជួយសង្គ្រោះជីវិតបាន១០នាក់ នៅពេលដែលជម្រើសផ្សេងទៀតនឹងអាចជួយជីវិតបានតែម្នាក់ប៉ុណ្ណោះ ព័ត៌មាននេះនឹងមានប្រយោជន៍ចំពោះអ្នកធ្វើសេចក្តីសម្រេច។ នៅក្នុងការប្រៀបធៀប ការកំណត់ជារូបិយវត្ថុមានការលំបាក និងជារឿយៗ មានការខ្វែងគំនិតគ្នាទៀតផង ឧទាហរណ៍ ដូចជាការកំណត់តម្លៃជាផលចំណេញទាក់ទងនឹងបរិស្ថាន។

ការកំណត់បន្ទុកចំណាយ និងផលចំណេញ គឺជាដំណាក់កាលសំខាន់បំផុតដើម្បីធ្វើការប្រៀបធៀបជម្រើសនានា។ គួរចងចាំថា ជម្រើសទាំងអស់ត្រូវបានជ្រើសរើសឡើងដើម្បីសម្រេចនូវលទ្ធផលដូចគ្នា (ឬផលចំណេញ) និងបន្ទុកចំណាយដូចគ្នា។ តម្លៃមួយឯកតានៃផលចំណេញឬមួយឯកតានៃបន្ទុកចំណាយ នឹងមានតម្លៃស្មើគ្នាសម្រាប់ជម្រើសនិមួយៗ។ ដូច្នេះ ការកំណត់បរិមាណថាជម្រើសនីមួយៗមានជោគជ័យ/ប្រសិទ្ធភាព និងការកំណត់ភាពញឹកញាប់នៃជម្រើសនីមួយៗ ដែលនឹងដាក់បន្ទុកចំណាយ គឺដូចជាការកំណត់ពីចំណាត់ថ្នាក់នៃជម្រើសដែរ។

គោលបំណងនៃដំណាក់កាលនេះ គឺដើម្បីប្រមូល/ចងក្រងព័ត៌មានស្តីពីផលប៉ះពាល់នៃជម្រើសនីមួយៗ។ បើដូច្នេះ តើអ្វីជាឥទ្ធិពលនៃការទទួលយកជម្រើសនីមួយៗ (តើអ្វីត្រូវធ្វើឬផ្លាស់ប្តូរ)។ ផលប៉ះពាល់ទាំងនេះត្រូវវាស់វែងបានដូចជាភាពខុសៗគ្នា រវាងស្ថានភាពដើមគ្មានសកម្មភាពនិងស្ថានភាពនៅពេលបញ្ញត្តិកម្ម អនុលោមតាមការដែលសង្ឃឹមថាមានអ្វីកើតមានឡើង។ បើអនុវត្តបែបនេះ យើងត្រូវទទួលស្គាល់ថា បញ្ញត្តិកម្ម (និងជម្រើសដទៃទៀត) កម្រនឹងអនុវត្តបានល្អឥតខ្ចោះណាស់ ដូច្នេះ ប្រសិទ្ធភាពរបស់វាត្រូវការឲ្យមានការកំណត់ ជាជាងយើងសន្មត់ថាអនុវត្តបានមួយរយភាគរយ។

## ការបង្កើតស្ថានភាពដើម (Base Case)

RIA ពាក់ព័ន្ធនឹងការវាយតម្លៃជម្រើសជាគោលនយោបាយមួយឬច្រើនជាមួយអ្វីដែលនឹងកើតមានឡើងពេលអវត្តមានសំណើបញ្ញត្តិកម្ម នោះគឺស្ថានភាពដើម។

ការបង្កើតកម្រិតនៃបន្ទុកចំណាយនិងផលចំណេញនៅក្នុងស្ថានភាពដើម គឺមានសារៈសំខាន់ណាស់។ អ្នកត្រូវកាត់បន្ទុកចំណាយនឹងផលចំណេញទាំងនោះ ចេញពីបន្ទុកចំណាយនិងផលចំណេញនៃជម្រើសនីមួយៗ បើពុំនោះទេ អ្នកនឹងសន្មត់ខុសអំពីបន្ទុកចំណាយ និងផលចំណេញនៃជម្រើសទាំងនោះ ដោយធ្វើការរាប់បញ្ចូលទាំងបន្ទុកចំណាយនិងផលចំណេញដែលមានស្រាប់ក្នុងស្ថានភាពដើមដែលបន្ទុកចំណាយ និងផលចំណេញទាំងនេះពុំមែនជាលទ្ធផលនៃអន្តរាគមន៍របស់ជម្រើសនីមួយៗទេ។

ឧទាហរណ៍: ចូរពិចារណាលើបញ្ញត្តិកំណត់ឲ្យពាក់អាវសុវត្ថិភាពការពារជីវិតនៅលើទូក ដើម្បីកាត់បន្ថយការស្លាប់ដោយលង់ទឹក។ ម្ចាស់ទូកឬអ្នកប្រើប្រាស់ទូកជាច្រើន បានពាក់អាវសុវត្ថិភាពការពារជីវិតនេះដោយស្ម័គ្រចិត្តរួចហើយ។ ដូច្នេះពួកគេនឹងមិនលង់ទឹកស្លាប់ក្នុងគ្រោះថ្នាក់របៀបនេះទេ។ ការបញ្ចូលបន្ទុកចំណាយទៅក្នុងអាវសុវត្ថិភាពនេះគឺជាការបំប៉ោងបន្ទុកចំណាយ ហើយការបញ្ចូលវាទៅក្នុងការជួយសង្គ្រោះជីវិត ក៏ជាការបំប៉ោងផលចំណេញផងដែរ។

ស្ថានភាពដើមត្រូវបានកំណត់ដោយគ្រប់បញ្ញត្តិកម្មដែលមានស្រាប់រួមទាំងបទដ្ឋានសង្គមនិងវប្បធម៌ដែលមានឥទ្ធិពលលើឥរិយាបថ របស់មនុស្សដែលទទួលរងផលប៉ះពាល់ដោយសំណើបញ្ញត្តិកម្ម។ ការលើកឡើងអំពីអាវសុវត្ថិភាពការពារជីវិត វារួមបញ្ចូលនូវការព្រួយបារម្ភរបស់ឪពុកម្តាយចំពោះកូន សុវត្ថិភាពរបស់បុគ្គលិក ឬបទបញ្ជារបស់ក្លិបកំសាន្តតាមទូក។ ដោយឈរលើមូលដ្ឋានច្បាប់ដែលមានស្រាប់និងឥរិយាបថ ការប៉ាន់ស្មានអំពីកម្រិតដែលមានស្រាប់ឬការអនុវត្តតាមដោយស្ម័គ្រចិត្ត ដែលបង្កើតបានជាស្ថានភាពដើម សម្រាប់ការគណនាបន្ទុកចំណាយ។

ស្ថានភាពដើមសម្រាប់ផលចំណេញគួរត្រូវបានបង្កើតឡើង នៅពេលដែលយើងកំណត់បញ្ហា។ ក្នុងឧទាហរណ៍ខាងលើ ទំហំនៃបញ្ហាគឺចំនួនអ្នកស្លាប់ដោយសារលង់ទឹកដែលបានកើតឡើង នៅពេលដែលមនុស្សធ្លាក់ចេញពីទូក។ ការពាក់អាវសុវត្ថិភាពការពារជីវិតដោយស្ម័គ្រចិត្ត បានកាត់បន្ថយរួចហើយនូវទំហំនៃបញ្ហានេះ។ សកម្មភាពរបស់រដ្ឋាភិបាលដែលបានស្នើឡើងគ្រាន់តែបានបន្ថែមនូវការកាត់បន្ថយគ្រោះថ្នាក់ប៉ុណ្ណោះ ប៉ុន្តែវាមិនបានជួយសង្គ្រោះជីវិតមនុស្សដែលបានពាក់អាវសុវត្ថិភាពដោយស្ម័គ្រចិត្តរួចហើយនោះទេ។

## ប្រសិទ្ធភាព

កំហុសទូទៅក្នុងការធ្វើបញ្ញត្តិកម្ម គឺជាការសន្មតថា មានតែបញ្ញត្តិកម្មទេ ដែលនឹងត្រូវឆ្លើយតបជាមួយបញ្ហាដែលបានកំណត់។ កំហុសនេះ កើតឡើងដោយមូលហេតុពីរយ៉ាង :

• បញ្ញត្តិកម្មមិនល្អឥតខ្ចោះនោះទេ: វាអាចជួយកាត់បន្ថយហានិភ័យចំពោះបញ្ហាដែលកើតមានឡើង ប៉ុន្តែ វាមិនអាចលុបបំបាត់បញ្ហាទាំងអស់បានទេ ដោយសារតែហានិភ័យដែលយើងមិនអាចគ្រប់គ្រងបានការមិនអនុវត្តតាម ឬកត្តាដទៃទៀត។

• ជារឿយៗជម្រើសដទៃទៀត ក៏អាចយកមកអនុវត្តដូចបញ្ញត្តិកម្មដែរ ប៉ុន្តែ ជម្រើសទាំងនោះមិនត្រូវបានយកមកពិចារណាឲ្យបានទូលំទូលាយ ដោយសារតែបានសម្រេចធ្វើបញ្ញត្តិកម្មនោះរួចហើយ។

ការកំណត់ជាបរិមាណនូវឥទ្ធិពលនៃជម្រើសនីមួយៗ អាចជួយបង្ការនូវកំហុសឆ្គងទាំងនេះ និងបានផ្តល់ព័ត៌មានដ៏ប្រសើរដល់អ្នកធ្វើសេចក្តីសម្រេច។

PA ឬ RIS នឹងផ្តល់ឲ្យអ្នកធ្វើសេចក្តីសម្រេចនូវព័ត៌មានគ្រប់គ្រាន់ថាតើជម្រើសនីមួយៗឆ្លើយតបជាមួយបញ្ហារបៀបណា។ ប្រសិទ្ធភាពនៃជម្រើសនីមួយៗនឹងត្រូវផ្អែកលើ ៖

• ការពង្រឹងការអនុវត្ត និងការប្រតិបត្តិតាម: ជម្រើសនឹងដោះស្រាយបញ្ហានៅពេលណាដែលជម្រើសត្រូវបានអនុវត្តប៉ុណ្ណោះ។ ដូច្នេះ ការប្រតិបត្តិតាមឲ្យបាន១០០% កម្រនឹងសម្រេចបានណាស់ ដោយសារហេតុផលជាច្រើន ដូចជាការលំបាកក្នុងការពង្រឹងការអនុវត្ត ឬវិសាលភាពមានកម្រិត (ឧ. នៅពេលដែលជម្រើសមិនបានអនុវត្តទៅលើគ្រប់ប្រជាជនទាំងអស់ដែលរងផលប៉ះពាល់ដោយសារបញ្ហា ដូចជាគម្រោងស្ម័គ្រចិត្តជាដើម)។

• តើហានិភ័យនៃបញ្ហាមានប៉ុន្មានដែលត្រូវដោះស្រាយ -សកម្មភាពនៃបញ្ញត្តិកម្ម ជាទូទៅត្រូវកំណត់ពីបុព្វហេតុជាក់លាក់នៃបញ្ហា ដូច្នេះ សូម្បីតែបុព្វហេតុទាំងនោះត្រូវបានដោះស្រាយក៏ដោយ បញ្ហានៅតែមានដដែល ដោយសារតែមានកត្តាដែលមិនអាចគ្រប់គ្រងបាន ដូចជាបរិស្ថានជាដើម។

ដោយសារតែ PA / RIS កំពុងវាយតម្លៃ ថាតើគំនិតផ្តួចផ្តើមថ្មីនឹងដំណើរការបានល្អរបៀបណានាពេលអនាគត ដូច្នេះ ព័ត៌មានស្តីពីប្រសិទ្ធភាពរបស់វាអាចមិនទាន់មាននៅឡើយ។

ការប៉ាន់ស្មានប្រសិទ្ធភាពនៃបញ្ញត្តិកម្ម អាចផ្អែកលើភស្តុតាងដែលបានមកពីការអនុវត្តបញ្ញត្តិកម្មស្រដៀងគ្នានៅបរទេស ចំណេះដឹងអំពីឧស្សាហកម្ម ក្រុមអ្នកប្រតិបត្តិតាមបញ្ញត្តិកម្ម និងការយល់ដឹងពីបុព្វហេតុនៃបញ្ហា។

• សំណើបញ្ញត្តិកម្មអាចត្រូវបានអនុវត្តរួចហើយ នៅបណ្តាប្រទេសមួយចំនួន។ ការវាយតម្លៃពីភាពជោគជ័យនៃបញ្ញត្តិកម្មនៅក្នុងប្រទេសទាំងនោះ អាចយកមកប្រើប្រាស់ដើម្បីប៉ាន់ស្មានការវាយតម្លៃផលប៉ះពាល់ដែលអាចកើតមានលើសំណើបញ្ញត្តិកម្មនៅក្នុងប្រទេសកម្ពុជា។

• ឧស្សាហកម្មដែលប្រតិបត្តិតាមបានល្អ អាចរំពឹងថានឹងបន្តអនុវត្តល្អតទៅទៀត។ ដូច្នេះចំណេះដឹងស្តីពីឧស្សាហកម្ម ឬក្រុមដែលរងផលប៉ះពាល់អាចមានប្រយោជន៍សម្រាប់វាយតម្លៃផលប៉ះពាល់។

• បញ្ញត្តិកម្មភាគច្រើនព្យាយាមដោះស្រាយហានិភ័យ ចំពោះសុខភាពមនុស្ស បរិស្ថាន។ល។ បុព្វហេតុដែលត្រូវបានដោះស្រាយ អាចមិនមែនជាបុព្វហេតុតែមួយគត់សម្រាប់ហានិភ័យទាំងនេះទេ។ ឧទាហរណ៍ អាកាសធាតុអាចបង្កឲ្យមានហានិភ័យនៃគ្រោះថ្នាក់នៅតាមដងផ្លូវ ឬការបំពុលបរិស្ថាន។ បញ្ញត្តិកម្មមិនអាចគ្រប់គ្រងអាកាសធាតុបានទេ ដូច្នេះប្រហែលជា PA/RIS មួយចំនួនត្រូវទទួលស្គាល់ថា ហានិភ័យខ្លះនឹងនៅតែមានដដែល ទោះបីជាបញ្ញត្តិកម្មត្រូវបានអនុវត្តក៏ដោយ។

## ការសន្មត

ជារឿយៗ ភស្តុតាងអំពីមូលហេតុដើមឬប្រសិទ្ធភាពនៃជម្រើស គឺមិនអាចរកបានទេ។ ដូច្នេះ ក្រសួងអាចសន្មតការគណនាបរិមាណដើម្បីធ្វើការវិភាគ។

នៅពេលដែលមានការសន្មតរួចហើយ ការសន្មតនោះគួរចែងឲ្យបានជាក់លាក់ និងគួរពន្យល់ឲ្យបានច្បាស់លាស់អំពីឥទ្ធិពលរបស់វាទៅលើលទ្ធផល (គឺថាលទ្ធផលគួរតែមានគុណភាព ដោយមានការបញ្ជាក់ពីហានិភ័យ)។ ដូច្នេះវានឹងអាចជួយទប់ស្កាត់អ្នកធ្វើសេចក្តីសម្រេចកុំឲ្យបកស្រាយ PA/RIS ខុស។

ការសន្មតគួរត្រូវបានធ្វើតេស្តដើម្បីឲ្យដឹងថា តើឥទ្ធិពលអ្វីនឹងធ្វើឲ្យមានការប្រែប្រួលទៅលើការសន្មត ដែលនឹងមានទៅលើលទ្ធផលដែលត្រូវតែវាយតម្លៃ។ ការសន្មតនេះអាចទទួលបានពីការដាក់ជំនួសតម្លៃខុសៗគ្នាសម្រាប់រាល់ការសន្មត និងបានទទួលតម្លៃដែលឆ្លើយតបនឹងលទ្ធផល។

## ការកំណត់តម្លៃបន្ទុកចំណាយនិងផលចំណេញ

ដំណាក់កាលចុងក្រោយនៃការវិភាគផលប៉ះពាល់ គឺវាយតម្លៃបន្ទុកចំណាយ និងផលចំណេញ។ ការកំណត់តម្លៃជារូបិយវត្ថុ អាចឲ្យយើងគណនា ចេញជាបន្ទុកចំណាយសរុបនិងផលចំណេញ ហើយអាចប្រៀបធៀបវាជាមួយនឹងជម្រើសនានាបាន។

ជាធម្មតា បន្ទុកចំណាយផ្ទាល់នៃបញ្ញត្តិកម្ម គឺងាយស្រួលក្នុងការគណនាតម្លៃ។ ឧ. មុខទំនិញដែលបានទិញ (បន្ទុកចំណាយ) ពេលវេលាធ្វើការរបស់បុគ្គលិក (ពេលវេលាដែលបានបំពេញការងារ គុណនឹងអត្រាប្រាក់ឈ្នួល) និងបន្ទុកចំណាយហិរញ្ញវត្ថុផ្ទាល់ (ដូចជាប្រាក់កម្រៃជាដើម)។

ផលចំណេញ និងបន្ទុកចំណាយមិនផ្ទាល់នៃបញ្ញត្តិកម្ម អាចមានការពិបាកក្នុងការកំណត់តម្លៃ។ សំណើបញ្ញត្តិកម្មមានគោលបំណងសំខាន់គឺដោះស្រាយភាពបរាជ័យក្នុងទីផ្សារ ឬក៏ផលប៉ះពាល់នៃការបែងចែក។ ដូច្នេះ ការប៉ាន់ស្មានផលចំណេញជាប់ពាក់ព័ន្ធនឹងការកំណត់តម្លៃអ្វីមួយមានការពិបាកពីព្រោះតម្លៃមួយចំនួនគ្មានកំណត់ក្នុងទីផ្សារ។ ដើម្បីប៉ាន់ស្មានតម្លៃទាំងនេះ យើងមានបច្ចេកទេសជាច្រើនយកមកប្រើប្រាស់ ដូចជា វិធីសាស្ត្រឆន្ទៈក្នុងការទូទាត់ (Willingness-to-pay)។

ការប៉ាន់ស្មានតម្លៃនៃផលចំណេញអាចធ្វើឲ្យមានបន្ទុកចំណាយ។ ប្រព័ន្ធ RIA ដែលមានប្រសិទ្ធភាពត្រូវធានាថា ការខិតខំប្រឹងប្រែងដែលចំណាយលើការវិភាគផលប៉ះពាល់ ត្រូវសមាមាត្រនឹងផលប៉ះពាល់នៃបញ្ញត្តិកម្មដែលយើងរំពឹងទុក។

សម្រាប់RIAនៅក្នុងប្រទេសកម្ពុជា យើងសង្ឃឹមថា ការប៉ាន់ស្មានភាគច្រើននៃផលចំណេញចេញមកពីការស្រាវជ្រាវដែលមានស្រាប់ ឬការគណនាដែលងាយស្រួល។ ក្នុងករណីនេះ បន្ទុកចំណាយនិងផលចំណេញនៃជម្រើសនីមួយៗ ត្រូវបានគណនា (បរិមាណ x តម្លៃមួយឯកតា)។ បន្ទុកចំណាយនិងផលចំណេញទៅអនាគត នឹងត្រូវបានកែតម្រូវដោយអត្រាអប្បហារដែលឆ្លុះបញ្ចាំងពីការពិតថា ជាទូទៅ ប្រជាជនឲ្យតម្លៃខ្ពស់ទៅលើចំណាយនៃការប្រើប្រាស់បច្ចុប្បន្នជាងទៅថ្ងៃក្រោយ ។ ការសរុបអំពីការកែតម្រូវបន្ទុកចំណាយ និងផលចំណេញសម្រាប់ជម្រើសនីមួយៗ នឹងផ្ដល់នូវរង្វាស់ដែលអាចយកមកប្រើប្រាស់ដើម្បីផ្ដល់ព័ត៌មានដល់ការធ្វើសេចក្ដីសម្រេច។

នៅពេលដែលផលចំណេញមិនអាចគិតជាតម្លៃបាន ការវិភាគប្រសិទ្ធភាពនៃតម្លៃ ការវិភាគស្ថានភាពរួមដើម និង/ឬការវិភាគតាមបែបគុណភាពអាចយកមកប្រើប្រាស់បាន។

## ការវិភាគប្រសិទ្ធភាពនៃតម្លៃ (Cost effectiveness analysis)

ការវិភាគប្រសិទ្ធភាពនៃតម្លៃ ត្រូវបានប្រើប្រាស់ដើម្បីប្រៀបធៀបជម្រើសពីរឬច្រើន នៅពេលដែលផលចំណេញមិនអាចត្រូវបានគណនាជាតម្លៃដោយងាយស្រួល ប៉ុន្តែអាចត្រូវបានកំណត់ជាបរិមាណវិញ។

ជម្រើសប្រសិទ្ធភាពនៃតម្លៃ គឺជាអនុបាត(ratio) រវាងបន្ទុកចំណាយនិងបរិមាណនៃផលចំណេញ។ ផលធៀបនេះផ្ដល់ព័ត៌មានដល់អ្នកធ្វើសេចក្ដីសម្រេចថា តើបន្ទុកចំណាយប៉ុន្មានដើម្បីសម្រេចបានមួយឯកតានៃផលចំណេញ។ ដូច្នេះ អ្នកធ្វើសេចក្ដីសម្រេចអាចជ្រើសរើសថា គោលបំណងចំណាយអនុបាត(ratio)នេះ (ផលធៀប)នឹងសម្រេចលទ្ធផលនោះបាន។

ជម្រើសប្រសិទ្ធភាពនៃតម្លៃមានអនុបាត(ratio)ទាប នឹងត្រូវបានជ្រើសរើសយក ទោះបីជម្រើសដែលមានអនុបាត(ratio) ខ្ពស់ក៏អាចអនុវត្តបានបើអ្នកធ្វើសេចក្ដីសម្រេច ចង់ចំណាយច្រើនដើម្បីសម្រេចលទ្ធផលក៏ដោយ។

## ការវិភាគស្ថានភាពរួចដើម (Break-even analysis or BEA)

ការវិភាគស្ថានភាពរួចដើម (BEA) ត្រូវបានប្រើប្រាស់ដើម្បីវិនិច្ឆ័យ អំពីជម្រើសដែលចូលចិត្តជាងនោះបានដាក់បន្ទុកចំណាយទាប នៅពេលដែលផលចំណេញមិនអាចវាយតម្លៃបាន ឬប្រសិទ្ធភាពនៃបញ្ញត្តិកម្មមានភាពមិនច្បាស់លាស់។

BEA គឺជាការប្រៀបធៀបបរិមាណនៃផលចំណេញនិងបន្ទុកចំណាយដើម្បីបង្ហាញថា តើតម្លៃឬចំនួននៃផលចំណេញគួរត្រូវបានគិតគូរដូចម្ដេចបើយើងប្រៀបធៀបជាមួយបន្ទុកចំណាយ។ ឧទាហរណ៍: សំណើបញ្ញត្តិកម្មមួយនឹងត្រូវផ្ដល់ផលចំណេញ ១០០០០ដុល្លា ចំពោះថ្លៃដើម ប្រសិនមួយឯកតានៃផលចំណេញមានតម្លៃ១០០០ដុល្លា ដូច្នេះ វាត្រូវ ផ្ដល់ផលចំណេញច្រើនជាង១០ឯកតា។

តម្លៃឬចំនួននេះ ត្រូវតែប្រៀបធៀបនឹងទំហំនៃបញ្ហា និងតម្លៃនៃផលចំណេញដទៃទៀត ដើម្បីធ្វើតេស្តថា តើវាពិតដូចការរំពឹងទុកចំពោះថ្លៃដើមឬទេ។ ឧទាហរណ៍ បញ្ហាកើតឡើងតែ៥ដងក្នុងមួយឆ្នាំ។ ដូច្នេះ ជម្រើសដែលត្រូវការ១០ដងក្នុងមួយឆ្នាំសម្រាប់ថ្លៃដើម នឹងប្រហែលជាមិនយកមកអនុវត្តទេ។

## ការវិភាគតាមគុណភាព

ផលប៉ះពាល់ណាដែលគេមិនអាចគណនាជាតម្លៃបាន គឺប្រសើរបំផុតក្នុងការផ្តល់ឱ្យអ្នកធ្វើសេចក្តីសម្រេចនូវការពិភាក្សាជាគុណភាពទៅលើប៉ះពាល់នោះ និងទុកឲ្យអ្នកធ្វើសេចក្តីសម្រេចធ្វើការវិនិច្ឆ័យថា តើសំណើបញ្ញត្តិកម្មផ្តល់ផលចំណេញដែលអាចទទួលយកបានដែរឬទេ។

វិធីសាស្ត្រវិភាគតាមបែបពហុលក្ខណវិនិច្ឆ័យ (Multi-criteria Analysis -MCA) គឺជាបច្ចេកទេសវិភាគដែលគេនិយមប្រើសម្រាប់ធ្វើការវិភាគតាមគុណភាព ហើយធានាថាជម្រើសទាំងអស់ត្រូវបានវាយតម្លៃដោយត្រឹមត្រូវ និងដោយតម្លាភាព។ វាអាចប្រើប្រាស់បានដើម្បីប្រៀបធៀបជម្រើសនីមួយៗ ប៉ុន្តែដោយសារតែលក្ខណសត្យានុម័តនៃការដាក់ពិន្ទុMCA វាមិនអាចប្រើប្រាស់បានដើម្បីកំណត់ថា តើជម្រើសណាមួយនឹងផ្តល់ផលចំណេញដុលនោះទេ។

- ដោយហេតុផលនេះ វិធីសាស្ត្រ MCA ត្រូវប្រើប្រាស់រួមគ្នាជាមួយការវិភាគប្រសិទ្ធភាពនៃតម្លៃ ឬការវិភាគស្ថានភាពរួចដើម ដើម្បីជ្រើសរើសនូវជម្រើសដែលពេញចិត្តជាង។

វិធីសាស្ត្រ MCA ទាក់ទងនឹងការជ្រើសរើសលក្ខណវិនិច្ឆ័យច្រើនដើម្បីវាយតម្លៃទៅលើជម្រើសនានា។ ជម្រើសទាំងអស់នោះត្រូវបានដាក់ពិន្ទុសម្រាប់លក្ខណវិនិច្ឆ័យនីមួយៗ ហើយពិន្ទុសរុបត្រូវបានប្រើប្រាស់ដើម្បីប្រៀបធៀបជម្រើសទាំងនោះ។ តារាងខាងក្រោមបង្ហាញពីឧទាហរណ៍នៃការដាក់ពិន្ទុតាមវិធីសាស្ត្រ MCA ។

វិធីសាស្ត្រ MCA មិនគ្រាន់តែជាតារាងពិន្ទុប៉ុណ្ណោះទេ វិធីសាស្ត្រ MCA អាចជួយអ្នកធ្វើសេចក្តីសម្រេច លុះណាតែលក្ខណៈវិនិច្ឆ័យទាំងឡាយត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្ន និងការដាក់ពិន្ទុផ្អែកលើភស្តុតាងបានច្បាស់លាស់។ ការជ្រើសរើសលក្ខណៈវិនិច្ឆ័យ និងការដាក់ពិន្ទុគួរតែអនុវត្តតាមដំណាក់កាលកំណត់បញ្ហា ការកំណត់បរិមាណ និងការកំណត់តម្លៃដូចបានគណត់ខាងលើ ហើយការជ្រើសរើសគួរត្រូវបានពន្យល់ដោយប្រុងប្រយ័ត្ន។ ឧទាហរណ៍ពិន្ទុប្រៀបធៀបនៃជម្រើសផ្សេងៗគ្នាគួរតែសមាមាត្រទៅនឹងការកំណត់បរិមាណ បើមិនដូច្នោះទេ ការដាក់ពិន្ទុនេះនឹងមិនត្រឹមត្រូវទេ។

| | ជម្រើស ទី 1 | ជម្រើសទី 2 | ជម្រើស ទី 3 |
|---|---|---|---|
| លក្ខណវិនិច្ឆ័យ 1 | 3 | 5 | 2 |
| លក្ខណវិនិច្ឆ័យ 2 | 2 | 2 | 2 |
| លក្ខណវិនិច្ឆ័យ 3 | -1 | -2 | -3 |
| លក្ខណវិនិច្ឆ័យ 4 | -2 | -2 | -2 |
| សរុប | 2 | 3 | -1 |

## ការវិភាគតាមក្រុមក្នុងសង្គម

ទោះបីជាបញ្ញត្តិកម្មអាចផ្តល់ផលចំណេញដុលដល់សហគមន៍ទាំងមូលក៏ដោយ ជួនកាលវាក៏ប៉ះពាល់ដល់ក្រុមមួយចំនួនខុសៗគ្នាដែរ។ ជាពិសេស នៅពេលដែលបញ្ញត្តិកម្មត្រូវបានព្រាងឡើង ដោយមិនបានគិតគូរពីបញ្ហាយេនឌ័រ វាអាចប៉ះពាល់ដល់យេនឌ័រមួយច្រើនជាងយេនឌ័រដទៃទៀត។ ឧទាហរណ៍:

- ការបង្កើនប្រាក់ឈ្នួលអប្បបរមា អាចប៉ះពាល់ទៅដល់ស្ត្រីច្រើន ប្រសិនបើភាគច្រើននៃបុគ្គលិកដែលមានប្រាក់ឈ្នួលទាបជាស្ត្រី។
- បញ្ញត្តិកម្មដែលប៉ះពាល់ដល់មីក្រូឥណទាន អាចប៉ះពាល់ដល់ស្ត្រីច្រើន ប្រសិនបើភាគច្រើននៃអ្នកទទួលឥណទានជាស្ត្រី។

បញ្ញត្តិកម្មអាចប៉ះពាល់ខុសៗគ្នាដល់តំបន់សាសនា ឬក្រុមវប្បធម៌ផ្សេងៗគ្នា។ ដោយសារតែផលប៉ះពាល់ខុសៗគ្នានេះ ការវាយតម្លៃសំណើបញ្ញត្តិកម្មដែលប៉ះពាល់មិនល្អដល់ក្រុមមួយ គឺជាផ្នែកមួយដ៏សំខាន់នៃការវិភាគផលប៉ះពាល់ទាំងក្នុងPA ទាំងក្នុងRIS។ តាមពិត ការវិភាគផលប៉ះពាល់ទៅលើយេនឌ័រ គឺជាការតម្រូវតាមច្បាប់ ហើយរបាយការណ៍ផលប៉ះពាល់ យេនឌ័រ(GIS) គួរតែរៀបចំនិងបញ្ចូលទៅក្នុងRISប្រសិនបើមានផលប៉ះពាល់សំខាន់ទៅលើយេនឌ័រទាំងពីរ។

ការវិភាគផលប៉ះពាល់ទៅលើក្រុមដោយឡែកណាមួយ អាចធ្វើឡើងជាទម្រង់នៃការវិភាគផលប៉ះពាល់ ដែលបានបង្ហាញពីមុនរួចមកហើយនៅក្នុងការណែនាំនេះ។ ពោលគឺ ការវិភាគគួរតែ :

- កំណត់ថា តើសំណើបញ្ញត្តិកម្មនោះប៉ះពាល់យ៉ាងដូចម្តេចដល់ក្រុមពាក់ព័ន្ធ និងតើវាខុសគ្នាដូចម្តេចទៅនឹងផលប៉ះពាល់ទៅលើប្រជាជនទូទៅ។
- កំណត់ចំនួនមនុស្សក្នុងក្រុមនោះ និងទំហំនៃផលប៉ះពាល់ខុសៗគ្នាទៅលើក្រុមនោះ។
- វាយតម្លៃផលប៉ះពាល់អវិជ្ជមាន (ឬវិជ្ជមាន) ទៅលើក្រុមនោះ។

ក្រុមដែលរងផលប៉ះពាល់ គួរតែពិគ្រោះយោបល់ដាច់ដោយឡែកពីគ្នាដែរ ដើម្បីកត់ត្រាទុកនូវគំនិតរបស់ពួកគេទៅលើសំណើបញ្ញត្តិកម្ម និងដើម្បីស្វែងរកនូវព័ត៌មានត្រឡប់ថា តើផលប៉ះពាល់ខុសៗគ្នានោះអាចត្រូវបានកាត់បន្ថយឬដោះស្រាយដោយរបៀបណា។

## ចំណុចទី ៥- ការពិគ្រោះយោបល់

ប្រសិនបើមិនមានការពិគ្រោះយោបល់ទេ ការយល់ដឹងរបស់យើងអំពីបញ្ហា ជម្រើស និងផលប៉ះពាល់នានា នឹងមានភាពខ្វះចន្លោះ។ ការពិគ្រោះយោបល់នឹងជួយដូចខាងក្រោម៖

- ធ្វើឲ្យប្រសើរឡើងនូវការយល់ដឹងអំពីបញ្ហា និងធ្វើឲ្យកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាលដោះស្រាយបញ្ហាតាមតម្រូវការ ដោយគិតបញ្ចូលទាំងការរិះរកនូវជម្រើសដទៃផ្សេងៗ។
- ជួយកំណត់អត្តសញ្ញាណនិងបរិមាណនៃផលប៉ះពាល់នៃកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល ដោយបង្កភាពងាយស្រួលក្នុងការប្រមូលទិន្នន័យនិងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងផលប៉ះពាល់នៃសំណើបញ្ញត្តិកម្ម ដែលនាំឲ្យជ្រើសរើសបាននូវជម្រើសដែលមានប្រសិទ្ធភាពបំផុត។
- បញ្ចៀសនូវហានិភ័យទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល ដែលអាចនឹងធ្វើឲ្យកិច្ចអន្តរាគមន៍ទាំងនោះមានប្រសិទ្ធភាពតិច។
- លើកកម្ពស់តម្លាភាពនិងទំនុកចិត្ត តាមរយៈការបើកចំហនូវស្មារតីនៃការសម្រេច ការសន្មត និងការវិភាគ ដើម្បីធ្វើការសម្រេចផ្សេងៗ។

ការពិគ្រោះយោបល់មិនទាមទារមានសំណួរចំនួនច្រើនលើសលប់ ដែលតម្រូវឲ្យអ្នកពាក់ព័ន្ធបំពេញនោះទេ។ វាមានប្រសិទ្ធភាពច្រើនជាង ដោយគ្រាន់តែសួរសំណួរសំខាន់ៗចំនួនតិចតួចល្មមប៉ុណ្ណោះ ទៅកាន់បុគ្គលដែលជាគោលដៅពិតប្រាកដ តាមរយៈវេទិកាពិគ្រោះយោបល់។

## បញ្ជីត្រួតពិនិត្យ- ធ្វើដូចម្តេចដើម្បីឲ្យការពិគ្រោះយោបល់មានប្រសិទ្ធភាព?

ធានាថាការពិគ្រោះយោបល់ត្រូវបានធ្វើឡើងជាមួយតំណាងភាគីទាំងអស់ដែលរងផលប៉ះពាល់ពីបញ្ហានិងពីសំណើបញ្ញត្តិកម្ម ដែលរាប់បញ្ចូលទាំងធុរកិច្ច រាជរដ្ឋាភិបាល សាធារណជន និង អង្គការតំណាងនានា។

ការពិគ្រោះយោបល់ត្រូវធ្វើឡើងច្រើនដង នៅក្នុងដំណើការនៃការតាក់តែងបញ្ញត្តិកម្ម។ ការពិគ្រោះយោបល់អាចជួយសម្រួលដល់ការកំណត់រកជម្រើស និងការកំណត់គោលដៅ ក៏ដូចជាធ្វើឲ្យប្រសើរឡើងនូវការវិភាគផលប៉ះពាល់ និងកំណត់បញ្ហានៃការអនុវត្ត។

ត្រូវយកចិត្តទុកដាក់ថា អ្នកពាក់ព័ន្ធទាំងឡាយសុទ្ធតែគិតលើផលប្រយោជន៍ក្នុងអំឡុងពេលពិគ្រោះយោបល់។ អាស្រ័យហេតុនេះ យើងត្រូវបើកចិត្តឲ្យទូលាយ និងត្រូវធ្វើការពិនិត្យពិច័យឲ្យបានល្អិតល្អន់ចំពោះរាល់ការលើកឡើងនានារបស់ពួកគេ។

## ពិគ្រោះយោបល់ជាមួយអ្នកណាខ្លះ?

អ្នកពាក់ព័ន្ធដែលគួរពិគ្រោះយោបល់ជាមួយអាចមានច្រើនក្រុម ឬអាចជាក្រុមជាក់លាក់ណាមួយដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងPA/RISនីមួយៗ ។ ជាគោលការណ៍ណែនាំ ការពិគ្រោះយោបល់អាចធ្វើបានជាមួយអ្នកពាក់ព័ន្ធដូចខាងក្រោម៖

- ធុរកិច្ចដែលរងផលប៉ះពាល់ពីបញ្ញត្តិកម្ម -ជាអ្នកដែលគួរត្រូវបានពិគ្រោះយោបល់ជាមួយអំពីបន្ទុកចំណាយនិងការអនុវត្តជម្រើសនីមួយៗ។
- អ្នកប្រើប្រាស់និងបុគ្គលដទៃដែលរងឥទ្ធិពលពីបញ្ហាឬពីសំណើបញ្ញត្តិកម្ម -ជាអ្នកដែលអាចផ្តល់ភស្តុតាងនៃបញ្ហាឬប្រសិទ្ធភាពរបស់ជម្រើសនីមួយៗ។
- អង្គការតំណាងផ្សេងៗ (សភាពាណិជ្ជកម្ម ក្រុមឧស្សាហកម្ម សមាគមអ្នកប្រើប្រាស់ អង្គការមិនមែនរដ្ឋាភិបាល) ដែលអាចមានលទ្ធភាពផ្តល់ឲ្យអ្នកនូវទស្សនវិស័យទូលំទូលាយ។
- ទីភ្នាក់ងាររដ្ឋាភិបាលទាំងឡាយ ដែលនឹងជួយជ្រោមជ្រែងក្នុងការអនុវត្តសំណើបញ្ញត្តិកម្ម (វិទ្យាស្ថានស្តង់ដាកម្ពុជា នគរបាល ភ្នាក់ងារគយ ឬក្រសួងដទៃទៀត)។
- ទីភ្នាក់ងាររដ្ឋាភិបាលទាំងឡាយ ដែលគ្រប់គ្រងឧស្សាហកម្មដូចគ្នា ដើម្បីធានាថាសំណើបញ្ញតិកម្មរបស់អ្នកមិនជាន់សមត្ថកិច្ចជាមួយបញ្ញត្តិកម្មដែលមានស្រាប់ ក៏ដូចជាបទប្បញ្ញតិអន្តរជាតិផ្សេងៗ។
- ក្រុមការងារយេនឌ័រ និងក្រុមការងារបញ្ជ្រាបយេនឌ័រនៅក្នុងស្ថាប័នរបស់អ្នក និងនៅក្នុងក្រសួងកិច្ចការនារី ដើម្បីធានាថា រាល់ផលប៉ះពាល់ទៅលើយេនឌ័រត្រូវបានទទួលស្គាល់។
- បណ្ឌិតសភាឬអ្នកឯកទេសដទៃទៀត ដែលយល់ដឹងច្បាស់អំពីវិស័យដែលនឹងត្រូវបានគ្រប់គ្រងដោយសំណើបញ្ញត្តិកម្ម ជាអ្នកដែលអាចបង្ហាញទស្សនៈមិនលំអៀង ឬអាចយល់ដឹងអំពីបញ្ញតិកម្មស្រដៀងគ្នានៅក្នុងប្រទេសផ្សេងទៀត។

ត្រូវយកចិត្តទុកដាក់ថា អ្នកពាក់ព័ន្ធទាំងឡាយសុទ្ធតែគិតពីផលប្រយោជន៍ដល់ការពិគ្រោះយោបល់ អាស្រ័យហេតុនេះ ត្រូវបើចិត្តឲ្យទូលាយ និងត្រូវធ្វើការពិនិត្យពិច័យអោយបានល្អិតល្អន់ ចំពោះរាល់ការលើកឡើងនានារបស់ពួកគេ។ អ្នកមិនចាំបាច់យល់ស្របទៅនឹង ទស្សនៈរបស់ពួកគេទេ ក៏ប៉ុន្តែអ្នកត្រូវតែទទួលយកមកពិចារណា និងធ្វើការឆ្លើយតបទៅពួកគេវិញ។

ព័ត៌មានផ្តល់ដោយអ្នកពាក់ព័ន្ធមានប្រសិទ្ធភាពបំផុតនៅពេលដែលវាត្រូវបានផ្សព្វផ្សាយជាមួយ PA/RIS ទោះបីជាក្នុងទម្រង់សង្ខេបក៏ដោយ។ យ៉ាងណាមិញ យើងត្រូវគោរពសំណើសុំរក្សាការសម្ងាត់របស់អ្នកពាក់ព័ន្ធ។

## ទម្រង់នៃការពិគ្រោះយោបល់

ការពិគ្រោះយោបល់អាចធ្វើឡើងក្នុងទម្រង់ជាច្រើនដូចជា កិច្ចប្រជុំ សិក្ខាសាលា វគ្គសិក្សា យោបល់ជាលាយលក្ខណ៍អក្សរ (អាចធ្វើឡើងតាមរយៈការផ្សាយជាសាធារណៈលើទំព័រកាសែត ឬទំនាក់ទំនងដោយផ្ទាល់ទៅកាន់អ្នកពាក់ព័ន្ធនីមួយៗ) ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមនានា។ ទម្រង់នៃការពិគ្រោះយោបល់ដែលអ្នកជ្រើសរើសគួរ ៖

- អនុញ្ញាតឲ្យមានការចូលរួមយ៉ាងទូលំទូលាយ ពីក្រុមអ្នកពាក់ព័ន្ធ ដើម្បីធានាថារាល់អ្នកពាក់ព័ន្ធ ដែលទទួលរងផលប៉ះពាល់ពីសំណើបញ្ញតិកម្ម ត្រូវបានពិគ្រោះយោបល់។
- បង្កើនរយៈពេលនៃដំណើរការតាត់តែងបញ្ញត្តិកម្ម ដើម្បីអនុញ្ញាតិឲ្យអ្នកពាក់ព័ន្ធអាចផ្ដល់មតិយោបល់អំពីជម្រើសទាំងឡាយ និងគោលដៅក៏ដូចជាសំណើបញ្ញត្តិកម្មចុងក្រោយ។
- ផ្ដល់ពេលវេលាគ្រប់គ្រាន់ និងរក្សាការសម្ងាត់ ដើម្បីអនុញ្ញាតឲ្យអ្នកពាក់ព័ន្ធអាចផ្ដល់យោបល់ជាលាយលក្ខណ៍អក្សរដោយមិនមានក្ដីបារម្ភថាព័ត៌មាននឹងត្រូវប្រើប្រាស់ខុសទិសដៅ ឧទាហរណ៍ អ្នកនឹងមានសំណូមពរពិគ្រោះយោបល់ជាមួយក្រុមខ្លះនៅក្នុងវេទិកាផ្សេងគ្នា។

## PA/RIS ជាឯកសារពិគ្រោះយោបល់

PA/RIS ជាឯកសារពិគ្រោះយោបល់ ក៏ដូចជាសេចក្ដីថ្លែងការណ៍អំពីសំណើរបស់រដ្ឋាភិបាលដែរ។ នេះជាការត្រូវចងចាំរាល់ពេលដែលអ្នកធ្វើសេចក្ដីព្រាងឯកសារទាំងពីរខាងលើ។

- ក្នុងពង្រាងត្រូវប្រើប្រាស់ភាសា ដែលអ្នកពាក់ព័ន្ធទាំងអស់អាចយល់បាន ដោយកុំដកស្រង់សេចក្ដីព្រាងបញ្ញតិកម្មតែម្ដង តែត្រូវអធិប្បាយថាតើសេចក្ដីព្រាងនេះនឹងដោះស្រាយបញ្ហាយ៉ាងដូចម្ដេច។
- ព័ត៌មានមួយចំនួនអំពីបញ្ហានិងផលប៉ះពាល់ អាចខ្វះខាតក្នុងអំឡុងពេលព្រាង PA/RIS បើដូច្នេះ អ្នកត្រូវរៀបចំសំណួរដើម្បីបានព័ត៌មានត្រឡប់ពីអ្នកពាក់ព័ន្ធ។
- រាប់បញ្ចូលផងដែរនូវលទ្ធផលនៃការពិគ្រោះយោបល់ដែលបានធ្វើឡើង ។

ព័ត៌មានទទួលបានពីអ្នកពាក់ព័ន្ធត្រូវប្រើប្រាស់ ដើម្បីបង្កើនគុណភាពនៃការវិភាគក្នុងអំឡុងពេលព្រាង រាប់បញ្ចូលទាំងក្រោយ RIS ត្រូវបានបោះពុម្ពផ្សាយផង។

## ចំណុចទី៦- សេចក្ដីសន្និដ្ឋាន

ខណៈដែលការវិភាគផលប៉ះពាល់បានចប់សព្វគ្រប់ ស្មារតីនៃជម្រើសផ្សេងៗ ដែលបានជ្រើសរើសមកពិចារណាគួរត្រូវធ្វើការប្រៀបធៀប។ ការវាយតម្លៃត្រូវយកមកគិតគូរនូវលទ្ធផលនៃការវិភាគផលប៉ះពាល់ នៃផលប៉ះពាល់លើក្រុមផ្សេងៗក្នុងសង្គម និងគុណភាពនៃភស្តុតាងដែលមាន។

ជម្រើសជាអនុសាសន៍ ត្រូវកំណត់ដោយការពន្យល់ថាតើហេតុអ្វីបានជាវាជាជម្រើសដែលឃើញសមស្របជាង ហើយក៏ត្រូវផ្ដល់មូលហេតុលម្អិតដែលបដិសេធជម្រើសផ្សេងៗទៀត។

ទម្រង់នៃសេចក្ដីសន្និដ្ឋាន នឹងផ្អែកលើវិធីសាស្ត្រដែលប្រើប្រាស់ក្នុងការវិភាគផលប៉ះពាល់៖

- ក្នុងករណីដែលមានការវិភាគបន្ទុកចំណាយនិងផលចំណេញ ការសន្និដ្ឋាននឹងធ្វើការប្រៀបធៀបផលចំណេញដុលរវាងជម្រើសនីមួយៗ (ផលចំណេញដកបន្ទុកចំណាយ) ដោយយកលទ្ធផលនេះជាមូលដ្ឋានក្នុងការជ្រើសរើសជម្រើសដែលចូលចិត្តជាង។
- ចំពោះ PA/RIS ដែលបង្ហាញបច្ច័យហានិភ័យខ្ពស់ថា ជម្រើសដែលឃើញជាងអាចជាជម្រើសមួយដែលនឹងកាត់បន្ថយហានិភ័យច្រើនបានយ៉ាងប្រសិទ្ធភាព ដោយមិនគិតពីបន្ទុកចំណាយ ជាពិសេសក្នុងករណីដែលផលចំណេញមិនអាចកំណត់តម្លៃជាប្រាក់បាន។
- ការវិភាគស្ថានភាពរួចដើមឬការវិភាគប្រសិទ្ធភាពនៃតម្លៃ អាចយកមកប្រើប្រាស់ ដើម្បីកំណត់ថាតើត្រូវបន្តជាមួយជម្រើសពិសេសណាមួយ ប៉ុន្តែការវិភាគទាំងនេះពិសេសគ្មានប្រយោជន៍ សម្រាប់ការប្រៀបធៀបជម្រើស ដែលទាមទារការវិភាគតាមគុណភាពនោះទេ។
- ពេលដែលការសម្រេចត្រូវបានធ្វើឡើង ដោយឈរលើមូលដ្ឋាននៃការវិភាគតាមគុណភាព បន្ទាប់មក លក្ខណវិនិច្ឆ័យនិងការវាយតម្លៃទៅលើជម្រើសនីមួយៗធៀបនឹងលក្ខណវិនិច្ឆ័យ ត្រូវបញ្ជាក់ឲ្យបានច្បាស់ឬក៏ប្រើប្រាស់ការវិភាគតាមបែបពហុលក្ខណវិនិច្ឆ័យវិញ។

ការសន្មតសំខាន់ៗត្រូវបានយកចិត្តទុកដាក់និងធ្វើតេស្តដោយប្រើប្រាស់តម្លៃជំនួស ដើម្បីធានាថាសេចក្ដីដ្ឋានដូចគ្នានៅរក្សាបានទោះបីជាស្ថិតក្នុងខណៈមិនប្រសើរក៏ដោយ។ យោបល់អ្នកពាក់ព័ន្ធមានប្រយោជន៍ដែលយើងមិនអាចចោលបាន ក្នុងករណីដែលយើងមិនច្បាស់លាស់ក្នុងចំណុចណាមួយ។

## ពិចារណាលើភាពមិនប្រាកដប្រជា

RIA ពាក់ព័ន្ធនឹងការសន្មតទៅលើអ្វីដែលនឹងកើតឡើងនាពេលអនាគត ដូចជា៖

- ទំហំនៃបញ្ហាដែលត្រូវដោះស្រាយ និងបញ្ញត្តិកម្មដែលមានប្រសិទ្ធភាពនឹងដោះស្រាយបញ្ហាបានយ៉ាងណា។
- ការផ្លាស់ប្តូរឥរិយាបថរបស់ធុរកិច្ចនិងបុគ្គលម្នាក់ៗ ដែលបណ្តាលមកពីបញ្ញត្តិកម្មថ្មីនេះ។

ការប្រែប្រួលតិចតួចនៃការសន្មតទាំងនេះ អាចធ្វើឱ្យជម្រើសផ្សេងទៅជាបានជ្រើសរើស។ សារៈសំខាន់នៃការសន្មតជាក់លាក់ទាំងឡាយ និងការប្រែប្រួលនៃសេចក្តីសន្និដ្ឋាន ដែលកើតចេញពីការកែតម្រូវការសន្មតទាំងនោះ ត្រូវកត់សម្គាល់ក្នុងសេចក្តីសន្និដ្ឋាន។ វាមានសារៈសំខាន់នៅពេលដែលអ្នកអាន PA/RIS មានព័ត៌មានដែលអាចប្រើប្រាស់ដើម្បីប៉ាន់ស្មានបន្ទុកចំណាយនិងផលចំណេញ។ ពេលមានការបង្ហាញសេចក្តីសង្ខេបនៃការសន្មតសំខាន់ៗ អញ្ជើញពួកគេឱ្យផ្តល់ព័ត៌មាន ត្រឡប់។

## ប្រើប្រាស់ភាសាសមស្រប

នៅក្នុងព្រះរាជាណាចក្រកម្ពុជា PA/RIS ភាគច្រើននឹងប្រើប្រាស់វិធីសាស្ត្របែបគុណភាពដើម្បីវិភាគផលប៉ះពាល់នៃជម្រើសទាំងឡាយ ដូចជាការវិភាគពហុលក្ខណវិនិច្ឆ័យ ឬការពិភាក្សាយ៉ាងលំអិតអំពីជម្រើសនីមួយៗ។

ការបង្ហាញយ៉ាងត្រឹមត្រូវនូវលទ្ធផលនៃការវិភាគដោយប្រើប្រាស់វិធីសាស្ត្របែបគុណភាពមានសារៈសំខាន់ណាស់។ ឧទាហរណ៍ការវិភាគតាមគុណភាពមួយ គឺជាសេចក្តីថ្លែងការណ៍អំពីគំនិត និងការចង់បានរបស់អ្នកតាក់តែង។ ជម្រើសដែលត្រូវបានជ្រើសរើសគឺជាជម្រើសដែលឃើញសមស្របជាងក្នុងចំណោមជម្រើសនានាតែប៉ុណ្ណោះ ហើយវាក៏មិនត្រូវបង្ហាញថាប្រសើរពិតប្រាកដដែរ។

សេចក្តីសន្និដ្ឋានគួរចៀសវាងគឺការប្រើប្រាស់ពាក្យដែលបង្ហាញថាជម្រើសដែលត្រូវបានជ្រើសរើសមានលក្ខណៈប្រសើរពិតប្រាកដជាងជម្រើសដទៃទៀត ដូចជាថ្លែងថាវាជាជម្រើសដែលមាន "ផលចំណេញខ្ពស់បំផុត" "ល្អបំផុត" ឬ"មានផលចំណេញច្រើនជាងបន្ទុកចំណាយ"។ ការលើកឡើងបែបនេះអាចធ្វើទៅបាន លុះត្រាតែមានការវិភាគបន្ទុកចំណាយ និងផលចំណេញយ៉ាងស៊ីជម្រៅ។

និយាយឱ្យខ្លីគឺ ត្រូវមានភាពស្មោះត្រង់ចំពោះរាល់ការវិភាគដែលបានធ្វើឡើង។

## ចំណុចទី ៧- ការអនុវត្ត និងការតាមដាន

ចំណុចចុងក្រោយនៃRIA គឺការពិចារណាអំពីសេចក្តីលម្អិត ការងាយអនុវត្ត និងបញ្ហាផ្សេងៗដែលត្រូវដោះស្រាយ មុនពេលជម្រើសដែលឃើញសមស្របជាងត្រូវបានអនុម័ត។

ការកំណត់ផែនការសម្រាប់ការអនុវត្តនិងការតាមដាននៅក្នុងRIA អាចធ្វើឲ្យការតាក់តែងបញ្ញត្តិកម្មកាន់តែប្រសើរឡើង និងបញ្ចៀសរាល់បន្ទុកចំណាយដើម្បីប្រតិបត្តិតាមដែលមិនចាំបាច់។ ការនេះអាចបង្កើនប្រសិទ្ធភាពនៃបញ្ញត្តិកម្ម ដោយសារយើងមានផែនការដើម្បីទប់ស្កាត់ឧបសគ្គផ្សេងៗជាមុន។

សម្រាប់ចំណុចចុងក្រោយនេះនៅក្នុងPAឬRIS ដំណើរការនៃការអនុវត្តត្រូវអធិប្បាយដោយរាប់បញ្ចូល៖

- កាលបរិច្ឆេទដែលបញ្ញត្តិកម្មនឹងមានសុពលភាព។
- សេចក្តីលម្អិតអំពីនាយកដ្ឋាន/ទីភ្នាក់ងារដែលនឹងគ្រប់គ្រង និង/ឬដាក់ឱ្យអនុវត្តសំណើបញ្ញត្តិកម្ម និងតួនាទីរបស់ពួកគេ។
- ប្រភពព័ត៌មានអំពីបញ្ញត្តិកម្ម ដែលសាធារណជនអាចពិគ្រោះយោបល់ដើម្បីយល់ដឹងបន្ថែមអំពីរបៀបប្រតិបត្តិតាមបញ្ញត្តិកម្ម (ឧទាហរណ៍ ធ្វើដូចម្តេចដើម្បីស្នើសុំអាជ្ញាបណ្ណ)។
- ការរៀបចំឱ្យមានមធ្យោបាយអន្តរកាលនានាដើម្បីកាត់បន្ថយផលប៉ះពាល់ដំបូងនៃបញ្ញត្តិកម្ម (ឧទាហរណ៍ការទាមទារឱ្យអនុវត្តកាតព្វកិច្ចយ៉ាងសន្សឹមៗ ការជូនព័ត៌មានទៅកាន់ធុរកិច្ចដែលទទួលរងផលប៉ះពាល់)។
- យន្តការតាមដានការអនុវត្តបញ្ញត្តិកម្ម រាប់បញ្ចូលទាំងការប្រើប្រាស់នូវការវាស់វែងលទ្ធផលនៃការអនុវត្ត និងការកំណត់ពេលវេលាសម្រាប់ការប្រមូលទិន្នន័យនិងធ្វើរបាយការណ៍។

ការអនុវត្តបញ្ញត្តិកម្មទាមទារនូវការកំណត់ផែនការយ៉ាងប្រុងប្រយ័ត្ន និងការងារផ្សេងៗទៀតជាច្រើន ព្រោះថាបញ្ញត្តិកម្មនឹងមិនមានសុពលភាពដោយងាយៗ តាមរយៈការចុះហត្ថលេខាដើម្បីឱ្យក្លាយទៅជាច្បាប់តែប៉ុណ្ណោះទេ។

ប្រសិនបើទីភ្នាក់ងារផ្សេងទៀតរបស់រដ្ឋាភិបាល តម្រូវឱ្យជួយដល់ការអនុវត្តបញ្ញត្តិកម្ម (ឧទាហរណ៍នគរបាល) ទីភ្នាក់ងារអនុវត្តត្រូវធានាថាអ្នកទាំងអស់នោះយល់ដឹងពីតួនាទីរបស់ខ្លួន និងមានសមត្ថភាពអនុវត្តរាល់ភារកិច្ចដែលតម្រូវសម្រាប់ពួកគេ។

# ឧបសម្ព័ន្ធ ១: ទម្រង់នៃការវាយតម្លៃបឋម

# ការវាយតម្លៃបឋម

## [បញ្ចូលឈ្មោះសំណើបញ្ញត្តិកម្ម]

## [បញ្ចូលឈ្មោះ ក្រសួង/ស្ថាប័ន]

លេខយោង: [បញ្ចូលលេខយោងដែលមានតែមួយគត់-មូលដ្ឋានទិន្នន័យ]

កាលបរិច្ឆេទចាប់ផ្តើម: [ថ្ងៃ - ខែ - ឆ្នាំ (គប្បីចាប់ផ្តើមឲ្យបានឆាប់បំផុត)

កាលបរិច្ឆេទបញ្ចប់ : [ថ្ងៃ - ខែ - ឆ្នាំ (នឹងត្រូវបញ្ជូនបន្តសម្រាប់ធ្វើការពិគ្រោះយោបល់)

ទំនាក់ទំនង:

| | ឈ្មោះ | លេខទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|
| IA-ទទួលបន្ទុក | | | |
| IA-ជំនួស | | | |
| ORIA-ទទួលបន្ទុក | | | |
| ORIA-ជំនួស | | | |

អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

| |
|---|
| |

តើសំណើនេះមានចរិកជាបញ្ញត្តិកម្មដែរឬទេ?

តើវាផ្លាស់ប្តូរឥរិយាបទធុរកិច្ចដែរឬទេ ? **មែន / មិនមែន**

| ច្បាប់ | | ព្រះរាជក្រឹត្យ | | អនុក្រឹត្យ | | ប្រកាស | | សេចក្តីសម្រេច | | សារាចរ | | ផ្សេងៗ (ពណ៌នា) |
|---|---|---|---|---|---|---|---|---|---|---|---|---|

សូមគូសសញ្ញាខ្វែងក្នុងប្រអប់ដែលត្រឹមត្រូវហើយ សូមពណ៌នាប្រសិនបើមានជម្រើសផ្សេងៗ។ ប្រសិនបើ "**មិនមែន**" ការវាយតម្លៃបឋមត្រូវបញ្ចប់រួចបន្តទៅទំព័រចុងក្រោយ / ប្រសិនបើ "**មែន**" បន្តទៅសំនួរបន្ទាប់។ (សូមគូសរង្វង់លើ "**មែន**" ឬ "**មិនមែន**")

តើសំណើបញ្ញត្តិកម្មនេះមានផលប៉ះពាល់លើវិស័យធុរកិច្ចដែរឬទេ? **មែន / មិនមែន**

ប្រសិនបើ "**មិនមែន**" សូមបញ្ចប់ការវាយតម្លៃបឋម(PA)រួចបន្តទៅទំព័រចុងក្រោយដើម្បីបញ្ចប់

បើ "**មែន**" សូមបន្តទៅសំនួរបន្ទាប់ហើយបន្តការវាយតម្លៃ។

*សូមគូសរង្វង់លើ "**មែន**" ឬ "**មិនមែន**"។*

**១. បញ្ហា- ហេតុអ្វីបានជាយើងធ្វើបញ្ញត្តិនេះឡើង?**

*សូមផ្តល់ភស្តុតាងជាក់ស្តែង ចៀសសវាងផ្តល់ជាមតិយោបល់ឬការពោលអះអាងអំពីបញ្ហា។ សូមគូសរង្វង់លើ "**មែន**" ឬ "**មិនមែន**"។*

| ប្រធានបទទូទៅ | បញ្ញត្តិនេះនឹងដោះស្រាយ | ភស្តុតាង/ភាពជាក់ស្តែង (សូមភ្ជាប់កំណត់សម្គាល់ប្រសិនបើចាំបាច់) |
|---|---|---|
| សុខភាពសាធារណៈ និងសុវត្ថិភាព | ☐មែន/ ☐មិនមែន | |
| ការការពារនិងអភិរក្សបរិស្ថាន | ☐មែន/ ☐មិនមែន | |
| សមធម៌យេនឌ័រ ការអភិរក្សសង្គម និងវប្បធម៌ | ☐មែន/ ☐មិនមែន | |
| ជម្រុញការប្រកួតប្រជែង | ☐មែន/ ☐មិនមែន | |
| ការប្រមូលផ្តុំព័ត៌មាន | ☐មែន/ ☐មិនមែន | |
| អនុលោមតាមកិច្ចព្រមរបស់ WTO និងកិច្ចព្រមព្រៀងអន្តរជាតិនានា | ☐មែន/ ☐មិនមែន | |

ប្រសិនបើមានបញ្ហាផ្សេងទៀត សូមអធិប្បាយនិងផ្តល់ភស្តុតាង

សូមបញ្ជាក់ថាតើបញ្ញត្តិកម្មនេះនឹងធ្វើឲ្យស្ថានការណ៍ប្រសើរឡើងយ៉ាងដូចម្តេច

**២. គោលបំណង - តើយើងចង់សម្រេចអ្វី?**

*ចូរបញ្ជាក់អំពីបំណងចុងក្រោយដែលមិនមែនគ្រាន់តែជាលទ្ធផលភ្លាមៗ។សូមផ្សារភ្ជាប់ទៅនឹងគោលបំណងនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។*

*ការកៀងគរចំណូលឬបង្កើតឥទ្ធិពលមិនមែនជាកម្មវត្ថុសមស្របរបស់បទប្បញ្ញត្តិឡើយ។ មិនត្រូវកំណត់គោលបំណងចង្អៀតពេកនិងរឹតត្បឹតជម្រើស តែក៏មិនត្រូវឲ្យទូលំទូលាយឬស្រពិចស្រពិលពេកដែរ។*

## ៣. ជម្រើស- ពិចារណាជម្រើសផ្សេងៗទាំងឡាយ

**៣.ក.** សូមរាយបញ្ជីនូវបញ្ញត្តិ(ដែលមានស្រាប់)ដែលពាក់ព័ន្ធឬប្រហាក់ប្រហែល។

| |
|---|
| ១. |
| ២. |

ចូរបញ្ជាក់ថាតើហេតុអ្វីបានជាលិខិតបទដ្ឋានទាំងនេះមិនទាន់គ្រប់គ្រាន់?

*តើលិខិតបទដ្ឋានទាំងនេះមិនដំណើរការឬ? តើយើងអាចកែលម្អដើម្បីសម្រេចបាននូវគោលបំណងដែលបានកំណត់ដែរឬទេ? តើយើងពិតជាចាំបាច់ត្រូវបង្កើតបទប្បញ្ញត្តិមួយផ្សេងទៀតដែរឬទេ?*

| |
|---|
| |

**<u>ជម្រើសដ៏ទៃទៀត</u>**

*ការស្វែងរកជម្រើសដ៏ទៃទៀតជាការសំខាន់ ហើយគួររំលឹកថាបញ្ញត្តិកម្មមិនមែនជាជម្រើសដំបូងបង្អស់នោះទេ។*

**៣.ខ.** ជម្រើសដ៏ទៃទៀតដែលអាចអនុវត្តបាន (សម្រាប់ការវិភាគលើផលប៉ះពាល់)

| |
|---|
| ១. |
| ២. |
| ៣. |

**៣.គ.** ជម្រើសដ៏ទៃទៀតដែលតាមទ្រឹស្តីអាចមាន ប៉ុន្តែមិនអាចនុវត្តបាន (មិនទាមទារនូវការវិភាគបន្ថែមទៀតទេលុះណាតែមានការប្រែប្រួលក្នុងអំឡុងពេលធ្វើការវាយតម្លៃផលប៉ះពាល់)

| |
|---|
| ៤. |
| ៥. |
| ៦. |

[*ក្រោយការពិគ្រោះយោបល់និងការវិភាគបន្ថែម ជម្រើសមួយចំនួនអាចត្រូវផ្លាស់ប្តូរពី(**៣.ខ**) មក (**៣.គ**) និងអាចបញ្ច្រាសមកវិញ*]

## ៤. ការប៉ាន់ស្មានបឋមលើចំណាយកាតព្វកិច្ចនិងផលប៉ះពាល់ចំពោះការប្រកួតប្រជែង

៤.១. <u>ការកំណត់នូវភារកិច្ច និងប្រភេទចំណាយ (tasks and cost-categories)</u>

*គោលការណ៍ណែនាំបានផ្តល់តារាងនៃប្រភេទចំណាយដែលអាចមាន*

| អត្ថាធិបាយអំពីជម្រើស | ភារកិច្ច និងប្រភេទចំណាយ ដែលវិស័យសាធារណៈត្រូវរ៉ាប់រងដើម្បីបង្កើត អនុវត្ត និង ប្រតិបត្តិជម្រើសនោះ | ភារកិច្ច និងប្រភេទចំណាយ ដែលវិស័យឧស្សាហកម្មត្រូវរ៉ាប់រងដើម្បីអនុវត្តតាមជម្រើសនោះ |
|---|---|---|
| ជម្រើសទី១:……………. | | |
| ជម្រើសទី២:……………. | | |
| ជម្រើសទី៣:…………….. | | |

៤.២. <u>វិសាលភាពនៃជម្រើស</u>

*ចូររៀបរាប់វិស័យឬប្រភេទធុរកិច្ចដែលរងឥទ្ធិពល ព្រមទាំងធ្វើការព្យាករណ៍ផលប៉ះពាល់ពីការអនុវត្តតាមជម្រើសដែលបានស្នើឡើង (សូមផ្តល់ភស្តុតាងដើម្បីគាំទ្រការប៉ាន់ស្មាននេះ)។*

| ជម្រើស | វិស័យធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| ជម្រើសទី១ | | | |
| ជម្រើសទី២ | | | |
| ជម្រើសទី៣ | | | |

៤.៣. <u>ប៉ាន់ស្មានកម្រិតកំណើននៃចំណាយកាតព្វកិច្ចរបស់ធុរកិច្ចនិងរបស់រាជរដ្ឋាភិបាល</u>

| **ធុរកិច្ច** | កម្រិតនៃចំណាយប្រតិបត្តិតាម | ផ្តល់អំណះអំណាង |
|---|---|---|
| ជម្រើសទី១ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | |
| ជម្រើសទី២ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | |
| ជម្រើសទី៣ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | |

| **រាជរដ្ឋាភិបាល** | កម្រិតនៃចំណាយប្រតិបត្តិតាម | ផ្តល់អំណះអំណាង |
|---|---|---|
| ជម្រើសទី១ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | |
| ជម្រើសទី២ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | |
| ជម្រើសទី៣ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | |

៤.៤. ប៉ាន់ស្មានកម្រិតនៃផលចំណេញ

| ជម្រើស | កម្រិតនៃផលចំណេញ | មូលហេតុ |
|---|---|---|
| ជម្រើសទី១ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | |
| ជម្រើសទី២ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | |
| ជម្រើសទី៣ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | |

៤.៥. តើមានផលប៉ះពាល់ដល់ការប្រកួតប្រជែងដែរឬទេ? **មែន** / **មិនមែន** *(គូសរង្វង់ និង យោងតាមគោលការណ៍ណែនាំ ផលប៉ះពាល់លើការប្រគួតប្រជែងតាមធម្មតាតម្រូវឲ្យធ្វើRIS)។*

| |
|---|
| |

៤.៦. តើមានផលប៉ះពាល់លើសមធម៌យេនឌ័រដែរឬទេ?

តើបញ្ញត្តិកម្មនេះមានឥទ្ធិពលមកលើស្ត្រី (ជាបុគ្គលម្នាក់ៗ ឬជាធុរជនដែលជាស្ត្រី) ច្រើនជាងបុរស ដែរឬទេ? **មែន** / **មិនមែន**

បើ "**មិនមែន**" សូមបន្តទៅផ្នែកទី៥

បើ "**មែន**" ចូរអធិប្បាយនូវផលប៉ះពាល់

| |
|---|
| |

តើផលប៉ះពាល់គួរឲ្យកត់សម្គាល់ដែរឬទេ? **មែន / មិនមែន**

បើ "**មិនមែន**" សូមបន្តទៅផ្នែកទី៥

បើ "**មែន**" ចូរបង្ហាញភស្តុតាងថាបញ្ញត្តិកម្មនេះពិតជាជះឥទ្ធិពលទៅលើស្ត្រីច្រើនជាង:

| |
|---|
| |

តើអ្នកអាចវាស់វែងផលប៉ះពាល់បានដែរ ឬទេ? **បាន / មិនបាន**

បើអាចធ្វើបាន ប្រាប់ពីបរិមាណ។

## ៥. កិច្ចពិគ្រោះយោបល់ដំបូង

ពិគ្រោះយោបល់ជាមួយតំណាងគំរូនៃអ្នកពាក់ព័ន្ធ។ កិច្ចពិគ្រោះយោបល់នេះមានគោលបំណងធ្វើឲ្យចំណុចដែលបានធ្វើខាងលើកាន់តែប្រសើរឡើង។ សេចក្តីលំអិតនៃកិច្ចពិគ្រោះយោបល់នេះអាចធ្វើឡើងតាមក្រោយ ប្រសិនបើតម្រូវឲ្យមានរបាយការណ៍ RIS ចុងក្រោយ។

ចូរធ្វើវាឲ្យដូចជាដំណើការប្រជុំប្រមូលគំនិត (brainstorming session) ឬការពិគ្រោះយោបល់ជាក្រុម (focus group interviews).

| ក្រុម | សហគ្រាស | វិធីសាស្ត្រ | សង្ខេបទស្សន: |
|---|---|---|---|
| ផលិតករ | សមាគមឧស្សាហកម្ម (តំណាង ឲ្យ% នៃឧស្សាហកម្ម) | | |
| | សហគ្រាស (ធំ/មធ្យម/តូច)<br>១.<br>២.<br>៣. | | |
| អ្នកប្រើប្រាស់ | ក្រុមអ្នកប្រើប្រាស់ | | |
| | អ្នកប្រើប្រាស់ធំៗ (ឧ. អ្នកប្រើប្រាស់ដែលជាឧស្សាហករ) | | |
| | អ្នកប្រើប្រាស់ចុងក្រោយ | | |
| រាជរដ្ឋាភិបាល | ក្រសួង/ស្ថាប័ន | | |
| យេនឌ័រ | ក្រុមស្ត្រី | | |
| អ្នកជំនាញ | ឈ្មោះ | | |
| ផ្សេងៗ | ឈ្មោះ | | |

## ៦.សន្និដ្ឋាន

៦.១. សេចក្តីសង្ខេបនៃការចំណាយបន្ថែមនិងផលចំណេញ

| ជម្រើស | បន្ទុកចំណាយរបស់វិស័យឧស្សាហកម្ម | បន្ទុកចំណាយរបស់វិស័យសាធារណៈ | ផលចំណេញ |
|---|---|---|---|
| ជម្រើសទី១: …………… | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ |
| ជម្រើសទី២: ……………. | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ |
| ជម្រើសទី៣: ……………. | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ | ☐គួរឲ្យកត់សម្គាល់<br>☐មិនគួរឲ្យកត់សម្គាល់ |

**៦.២. តើចាំបាច់ធ្វើRIS ដែរឬទេ?**

- **ចាំបាច់**- សូមបញ្ចប់ការវាយតម្លៃបឋម (PA) ហើយចាប់ផ្តើមរៀបចំ RIS។
- **មិនចាំបាច់**- ផ្តល់អំណះអំណាងនិងបំពេញការវាយតម្លៃបឋម (PA) ដែលនៅសេសសល់។

*(សូមគូសរង្វង់លើ "**ចាំបាច់**" ឬ "**មិនចាំបាច់**" ដោយផ្អែកទៅលើកម្រិតនៃភាពសំខាន់នៃចំណាយកាតព្វកិច្ចនិងផលចំណេញហើយពិចារណាផងថាតើមានផលប៉ះពាល់លើការប្រកួតប្រជែងដែរឬទេ)។*

| |
|---|
| ផ្តល់អំណះអំណាងសម្រាប់ការមិនរៀបចំធ្វើRIS |

៦.៣. ជម្រើសដែលបានជ្រើសរើស (សូមអធិប្បាយអំពីជម្រើស)

| |
|---|
| |

| លក្ខណៈវិនិច្ឆ័យ | | មូលហេតុ |
|---|---|---|
| តើវាជាជម្រើសដែលមានបន្ទុកចំណាយអប្បបរមាសម្រាប់វិស័យឧស្សាហកម្មនិងសហគមន៍ដែរឬទេ? | □មែន□មិនមែន | |
| តើជម្រើសនេះផ្តល់នូវផលចំណេញអតិបរមាដែរឬទេ? | □មែន□មិនមែន | |
| តើវាជាជម្រើសដែលមានហានិភ័យអប្បបរមាសម្រាប់សាធារណៈដែរឬទេ? | □មែន□មិនមែន | |

**ប្រសិនបើចម្លើយទាំងអស់សុទ្ធ "មែន" សូមបន្តទៅចំណុចទី៧។**

ប្រសិនបើមានចម្លើយណាមួយខាងលើ"**មិនមែន**"តើហេតុអ្វីបានជាជម្រើសនេះត្រូវបានជ្រើសរើស?*(សូមគូស "x" ក្នុងប្រអប់មួយ)*

□ទោះបីជាលក្ខណៈវិនិច្ឆ័យមួយឬពីរខាងលើវាអវិជ្ជមាន តែការរួមបញ្ចូលគ្នានៃលក្ខណៈវិនិច្ឆ័យទាំងអស់មានលក្ខណៈសមស្រប។ ចូរផ្តល់អំណះអំណាងនិងបន្តទៅចំណុចទី៧

□មានកត្តាផ្សេងទៀតមានឥទ្ធិពលលើការសម្រេចចិត្ត [មើលអត្ថបទខាងក្រោម]

តើកត្តាផ្សេងណាខ្លះត្រូវបានប្រើប្រាស់ក្នុងការជ្រើសរើសជម្រើសនេះ?

ចូរពន្យល់អំពីកាលៈទេសៈនិងបញ្ជាក់ពីអំណះអំណាង?

| កត្តាជះឥទ្ធិពល | កាលៈទេសៈ | អំណះអំណាង |
|---|---|---|
| | | |

## ៧. ការអនុវត្ត និងការតាមដាន

ប្រសិនបើជម្រើសបញ្ញត្តិកម្មត្រូវបានជ្រើសរើស៖

**៧.១.** តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាពនិងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

| |
|---|
| |

**៧.២.** តើគួរធ្វើការពិនិត្យបទប្បញ្ញត្តិនេះឡើងវិញក្រោយពេលបទប្បញ្ញត្តិនេះត្រូវបានប្រតិបត្តិ ដែរឬទេ? បើដូច្នោះ តើបទប្បញ្ញត្តិនេះគួរត្រូវបានពិនិត្យឡើងវិញយ៉ាងដូចម្តេច និងនៅពេលណា?

| |
|---|
| |

<u>អត្ថាធិប្បាយផ្សេងទៀត</u>

| |
|---|
| |

| ដំណើរការ | ឈ្មោះ | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|---|
| រៀបចំដោយ (ក្រសួងពាក់ព័ន្ធ) | | | |
| ត្រួតពិនិត្យដោយ (ORIA) | | | |
| ឯកភាពដោយ (ORIA) | | | |
| បញ្ចូលទិន្នន័យដោយ | | | |
| បញ្ចូលក្នុងគេហទំព័រដោយ | | | |

# ឧបសម្ព័ន្ធ ២: តារាងត្រួតពិនិត្យនៃការវាយតម្លៃបឋម

# ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៅប្រទេសកម្ពុជា
# សាវតារនៃការណែនាំ តារាងត្រួតពិនិត្យ

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតស្ថាប័នត្រួតពិនិត្យលិខិតបទដ្ឋានគតិយុត្ត ដែលក្នុងនោះក្រុមការងារអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តិ (ORIA) មានតួនាទីពិនិត្យមើលវិធីអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃបទដ្ឋានគតិយុត្តនៅព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃការបង្កើតអង្គភាពនេះ គឺដើម្បីធានាថាសំណើបញ្ញត្តិកម្មទទួលបាននូវការវិភាគជាប្រព័ន្ធ ដោយមានការវាយតម្លៃលើបន្ទុកចំណាយនិងផលចំណេញនៃសំណើទាំងនោះ ព្រមទាំងវិភាគលើជម្រើសនានាដើម្បីឈានទៅដល់ការសម្រេចប្រកបដោយពតិមានច្បាស់លាស់។ ដូចនេះ ORIA មានមុខងារសំខាន់ៗដូចជា ការវាយតម្លៃលើសំណើបញ្ញត្តិកម្ម (និងជម្រើសនានា) បណ្ដុះបណ្ដាលអំពីវិធីអនុវត្តការវិភាគផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA process) ដល់មន្ត្រីតាមបណ្ដាក្រសួង ការផ្សព្វផ្សាយរបាយការណ៍នៃការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តិ និងការសម្របសម្រួលជាមួយក្រសួងនានាព្រមទាំងទំនាក់ទំនងជាមួយផ្នែកឯកជន។

ជាដំបូង រាល់សំណើបញ្ញត្តិទាំងអស់ត្រូវបានយកមកពិនិត្យដើម្បីកំណត់ថាតើសំណើទាំងនោះមានចរិកជាបញ្ញត្តិកម្មឬយ៉ាងណា គឺថា តើរដ្ឋាភិបាលទំនងជានឹងមានឥទ្ធិពលដោយផ្ទាល់ឬដោយប្រយោលដល់ការងារធុរកិច្ចប្រចាំថ្ងៃដែរឬទេ ប្រសិនបើសំណើទាំងនោះនឹងត្រូវក្លាយទៅជាបញ្ញត្តិកម្ម។ ដូចនេះរាល់សំណើបញ្ញត្តិកម្មទាំងអស់ត្រូវឆ្លងកាត់ពីរដំណាក់កាលគឺៈ

- ការវាយតម្លៃបឋម (PA) ដែលត្រូវបានប្រើចំពោះរាល់សំណើបញ្ញត្តិកម្មទាំងអស់ (សូមមើលក្នុងប្រអប់ខាងក្រោម)។
- ប្រសិនជា PA បង្ហាញថាសំណើនោះទំនងជាមានផលប៉ះពាល់គួរកត់សម្គាល់ គឺអ្នកតាក់តែងបទប្បញ្ញត្តិត្រូវធ្វើការវាយតម្លៃពេញលេញ (RIS)។

ក្នុងការរៀបចំធ្វើ PA និង RIS គឺត្រូវធ្វើការវិភាគតាមចំណុចទាំង៧គឺ ***បញ្ហា គោលបំណង ជម្រើស ផលប៉ះពាល់ ពិគ្រោះយោបល់ សន្និដ្ឋាន និងការអនុវត្តនិងតាមដាន***។ ដំណាក់កាលទាំង៧នេះមានទំនាក់ទនងគ្នាទៅវិញទៅមក និងការធ្វើការវាយតម្លៃត្រូវធ្វើម្តងហើយម្តងទៀតដើម្បីឲ្យកាន់តែល្អ។

ORIA បានបង្កើតតារាងត្រួតពិនិត្យមួយ ឬ Checklist និងគោលការណ៍ណែនាំផ្សេងៗដើម្បីជួយដល់បណ្ដាក្រសួងក្នុងការអនុវត្ត RIA។ ឯកសារទាំងនេះនឹងចង្អុលបង្ហាញពីវិធីងាយស្រួលសម្រាប់ធ្វើ PA និង RIS។

Checklist ជាប់ពាក់ព័ន្ធជាមួយនឹង PA ពីព្រោះនៅពេលដែលសំណើបញ្ញត្តិកម្មមួយឈានដល់ដំណាក់ធ្វើ RIS នោះ PA ក៏ត្រូវបានធ្វើឡើងចប់ជាស្ថាពរហើយ ដូចនេះការវិភាគទៅតាមចំណុចទាំង៧ខាងលើក៏ត្រូវបានចប់រួចរាល់ហើយដែរ។

| |
|---|
| គោលបំណងដ៏ចម្បងរបស់ PA គឺវាយតម្លៃអំពីផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មដើម្បីកំណត់ថាមានតើផលប៉ះពាល់គួរកត់សម្គាល់ឬទេ។ ដូចនេះការវាយតម្លៃក្នុងដំណាក់កាលនេះមានលក្ខណៈសើៗនៅឡើយ។<br>មិនមានការវិភាគបន្ថែមទៀតទេចំពោះសំណើបញ្ញត្តិកម្មដែលមិនមានផលប៉ះពាល់គួរកត់សម្គាល់។ PA នឹងត្រូវដាក់ជូនទៅអ្នកធ្វើសេចក្តីសម្រេចដោយភ្ជាប់ជាមួយនូវសំណើបញ្ញត្តិកម្ម។ PA ក៏នឹងត្រូវដាក់បង្ហោះនៅលើគេហទំព័រផងដែរ។<br>សំណើបញ្ញត្តិកម្មដែលសំខាន់ត្រូវមាន RIS ដែលតម្រូវឲ្យមានការវិភាគយ៉ាងស៊ីជម្រៅបន្ថែម៕ |

## លំហូរ- ដំណើរការនៃការវាយតម្លៃបឋម



## បញ្ជីត្រួតពិនិត្យ( Checklist )សម្រាប់ការវាយតម្លៃបឋម( PA )

| ចំណុចសំខាន់ | អត្ថាធិប្បាយ | ការណែនាំ | • |
|---|---|---|---|
| **១.បញ្ហា**<br>ហេតុអ្វីបានជាបង្កើតបញ្ញត្តិកម្ម? | -មូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការវាយតម្លៃ<br>-បង្ហាញភស្តុតាង គឺមិនមែនជាការយល់ឃើញឬការអះអាងទេ | -តើខុសគ្នាអ្វីទៅប្រសិនបើមិនបង្កើតបញ្ញត្តិកម្ម?<br>-ហេតុអ្វីបានជាទីផ្សារមិនអាចដោះស្រាយបញ្ហាបាន?<br>-ហេតុអ្វីបានជាបញ្ញត្តិកម្មដែលមានស្រាប់ មិនអាចដោះស្រាយបញ្ហាបាន?<br>-តើបញ្ញត្តិកម្មដែលត្រូវបង្កើតនឹងធ្វើឲ្យស្ថានភាពកាន់តែល្អយ៉ាងដូចម្តេច?។ | |
| **២.គោលបំណង**<br>តើចង់សម្រេចបានអ្វី? | កំណត់គោលដៅចុងក្រោយ មិនមែនគោលដៅរបស់បញ្ញត្តិកម្មដែលត្រូវបង្កើតនោះទេ? | -អ្វីដែលត្រូវសម្រេច(លទ្ធផល) ប្រសើរជាងសម្រេចដោយ របៀបណា (វិធីសាស្ត្រ)<br>-ចៀសវាងការកំណត់គោលបំណងទូលាយពេក ឬចង្អៀតពេក | |
| **៣.ជម្រើស** | កំណត់ជម្រើសផ្សេងៗទាំងអស់ (និងអ្នកពាក់ព័ន្ធទាំងអស់) | កំណត់ប្រភេទជម្រើសដែលអាចធ្វើបាន និងមិនអាចធ្វើបាន។ | |
| **៤.ការវាយតម្លៃលើផលប៉ះពាល់** | -ពិចារណាពីផលប៉ះពាល់នៃជម្រើសនីមួយៗទៅលើអ្នកពាក់ព័ន្ធ<br>-ពិចារណាផលប៉ះពាល់ទៅលើសមភាពយេនឌ័រ | -កំណត់ជាបរិមាណនៃបន្ទុកចំណាយកាតព្វកិច្ចរបស់ធុរកិច្ច<br>-ប៉ាន់ស្មានបន្ទុកចំណាយនិងផលចំណេញរបស់ធុរកិច្ច រដ្ឋាភិបាល | |

| | | | |
|---|---|---|---|
| | -ពិចារណាផលប៉ះពាល់លើការប្រកួតប្រជែង•• | និងអ្នកប្រើប្រាស់។<br>ប៉ាន់ស្មានចំនួនស្ត្រីធ្វើការនៅរោងចក្រដែលទទួលរងផលប៉ះពាល់។ វាយតម្លៃថាតើស្ត្រីនឹងទទួលផលអវិជ្ជមានពីបញ្ញត្តិកម្មទេ។ | |
| **៥.ពិគ្រោះយោបល់** | -បញ្ចូលគ្រប់ដំណាក់កាលទាំងអស់ ជាពិសេសដំណាក់កាលទី៣ និងទី៤<br>-រួមបញ្ចូលបញ្ហាការប្រតិបត្តិតាមអង្គការពាណិជ្ជកម្មពិភពលោក<br>(ក្រសួងពាណិជ្ជកម្ម)<br>-ពិចារណាពីសមភាពយេនឌ័រ | -កំណត់អ្នកពាក់ព័ន្ធ<br>-សួរយោបល់ពីអ្នកពាក់ព័ន្ធតាមរយៈមធ្យោបាយសមរម្យ<br>-កត់ត្រា និងពិចារណាមតិយោបល់ទាំងនោះ។<br>-ពិគ្រោះជាមួយGMAC ក្រុមការងារយេនឌ័រ និងជាមួយ MWA<br>បើចាំបាច់។ | |
| **៦.សន្និដ្ឋាន** | ពិចារណាពីសម្ការភាពនៃផលប៉ះពាល់ | -ផលប៉ះពាល់គួរឲ្យកត់សម្គាល់ គឺបន្តវាយតម្លៃផលប៉ះពាល់របស់បញ្ញត្តិកម្ម និងរៀបចំរបាយការណ៍លម្អិត(RIS) វាយតម្លៃផលប៉ះពាល់របស់បញ្ញត្តិកម្ម ។បោះពុម្ពការវាយតម្លៃបឋម(PA)។<br>បើពុំនោះទេ បញ្ជាក់ថាការជ្រើសសំណើបញ្ញត្តិកម្មជាជម្រើសដ៏មានប្រសិទ្ធភាពបំផុត ដើម្បីដោះស្រាយបញ្ហា និងសម្រេចគោលបំណង។ ពិនិត្យបញ្ហានៃការអនុវត្ត។ | |

| | | | |
|---|---|---|---|
| | | | |
| **៧.ការអនុវត្ត និងតាមដាន** | ពិនិត្យឡើងវិញ/ត្រួតពិនិត្យក្រោយពេលអនុវត្ត | កំណត់កាលសុពលភាពនៃបញ្ញត្តិកម្ម?<br>បោះពុម្ពការវាយតម្លៃបឋម។ | |

•វាយតម្លៃប្រភេទនីមួយៗនិងផ្តល់កម្រិតគុណភាព ក.ល្អ / ខ.ទទួលយកបាន / គ.អន់ (ធ្វើឡើងវិញ)

••មកដល់ពេលនេះ គឺផ្តោតទៅលើបន្ទុកចំណាយ និងផលចំណេញ ប៉ុន្តែមានផលប៉ះពាល់លើការប្រកួតប្រជែងដែលអាចជាចំណុចគួរឲ្យកត់សម្គាល់ដែរ។ ប្រសិនបើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់លើការប្រកួតប្រជែង នោះនឹងតម្រូវឲ្យធ្វើរបាយការណ៍លម្អិត(RIS) វាយតម្លៃផលប៉ះពាល់របស់បញ្ញត្តិកម្ម។

ផលលើការប្រកួតប្រជែងកើតឡើង នៅពេលសំណើបញ្ញត្តិកម្មផ្លាស់ប្តូរទិដ្ឋភាពនៃការប្រកួតប្រជែង ដូចជាការរិតត្បិតលំហូរនៃធុរកិច្ចថ្មីចូលក្នុងទីផ្សារ ឬការផ្តល់ការអនុគ្រោះដល់ក្រុមហ៊ុនខ្លះច្រើនជាងក្រុមហ៊ុនផ្សេងទៀត (ក្រុមហ៊ុនធំមានប្រៀបជាងក្រុមហ៊ុនតូច)។ បញ្ហាទាំងនេះអាចមាន ដូចខាងក្រោម ៖

-តើអាចប៉ះពាល់ចំនួននិងកម្រិតនៃធុរកិច្ចនៅក្នុងទីផ្សារដែរឬទេ? **មែន / មិនមែន**

-តើអាចផ្លាស់ប្តូរលទ្ធភាពរបស់ធុរកិច្ចក្នុងការប្រកួតប្រជែងដែរឬទេ? **មែន / មិនមែន**

-តើអាចមានផលប៉ះពាល់លើអ្នកប្រើប្រាស់ដែរឬទេ? **មែន / មិនមែន**

ប្រសិនបើចម្លើយចំពោះសំនួរខាងលើនេះ**ថា"មែន"** គឺតម្រូវឲ្យធ្វើរបាយការណ៍លម្អិត(RIS) វាយតម្លៃផលប៉ះពាល់របស់បញ្ញត្តិកម្ម។

# ហិរញ្ញប្បទានគម្រោងដោយធនាគារអភិវឌ្ឍន៍អាស៊ី

ADB